# ព្រឹទ្ធសភា

# SENATE MAGAZINE

## ទស្សនាវដ្តីប្រចាំខែមករា



លេខ ២៦៧ ឆ្នាំទី២៣ ពុទ្ធសករាជ ២៥៦៦ គ្រិស្តសករាជ ២០២៣

Issue 267 Volume 23 Before Christ 2566 Common Era 2023

# មាតិកា

## សកម្មភាពថ្នាក់ដឹកនាំ




- សម្តេចវិបុលសេនាភក្តី សាយ ឈុំ អនុញ្ញាតឱ្យឯកអគ្គរាជទូតកម្ពុជាទើបតែងតាំងថ្មី ចំនួន៨រូបចូលជួបសម្តែងការគួរសម និងទទួលអនុសាសន៍.................................. ១


## សកម្មភាពគណៈកម្មការ




- គណៈកម្មការទី៧ព្រឹទ្ធសភាចុះឈ្វេងយល់ អំពីវឌ្ឍនភាពការងាររបស់រាជបណ្ឌិត្យសភាកម្ពុជា .................................................................... ៣
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ អញ្ជើញឈ្វេងយល់ និងប្រមូលព័ត៌មាននៅមូលដ្ឋានចំនួន៥ខណ្ឌ ដើម្បីរៀបចំវេទិកា ........................................................................................៥
- គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា ............................................................................ ៧
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស .....................................................................១០
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨.....................................................១១
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ ........................................................................................២៦
- ការងារទទួលពាក្យបណ្តឹង.......................................................................................................................២៨


## សកម្មភាពអគ្គលេខាធិការដ្ឋាន




- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែធ្នូ និងប្រចាំឆ្នាំ២០២២ ព្រមទាំងកំណត់ទិសដៅការងារឆ្នាំ២០២៣ ..........................២៩
- ឯកឧត្តម អ៊ុំ សារឹទ្ធ អនុញ្ញាតឱ្យនិស្សិតកម្ពុជា ទទួលជ័យលាភីអាហារូបករណ៍ប្រទេសនូវែលសេឡង់ ចូលជួបសំណេះសំណាល និងទទួលអនុសាសន៍ ........................................... ៣០
- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ ......................................................... ៣១



**អ្នកគ្រប់គ្រងទូទៅ**
ឯកឧត្តម អ៊ុំ សារឹទ្ធ

**អ្នកសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធ**
ឯកឧត្តម លីម ប៊ុនហុក
ឯកឧត្តម កែវ ចាន់ណា
ឯកឧត្តម សុខ រិទ្ធី
ឯកឧត្តម ជួន ណា
ឯកឧត្តម គឹម ពិសិដ្ឋ
លោក ជួន សុខធី
លោក ទេព មករា
លោក កុក វ៉ៃ

**អ្នកគ្រប់គ្រងផ្ទាល់**
លោក ទេព មករា

**ក្រុមអ្នកយកព័ត៌មាន**
ការិយាល័យព័ត៌មាន

**ការីកុំព្យូទ័រ**
លោក ជុំ ច័ន្ទរតនា
លោកស្រី សុខ សុជាតា


*ក្របមុខ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ថតរូបអនុស្សាវរីយ៍ជាមួយឯកអគ្គរាជទូតកម្ពុជា។*

*ក្របក្រោយ ៖ ទេសភាពអគារក្រហមវិមានព្រឹទ្ធសភា៕*


**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**
**វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**
**ទូរស័ព្ទ: (855) 23 211441, 211442, 211443, ទូរសារ: (855) 23 211446**
**E-mail : oumsarith.sgsenate@gmail.com**
**Website: www.senate.gov.kh**
**www.elibrary.senate.gov.kh**
**Facebook: www.facebook.com/senateofcambodia**

# សម្តេចវិបុលសេនាភក្តី សាយ ឈុំ អនុញ្ញាតឱ្យឯកអគ្គរាជទូតកម្ពុជា ទើបតែងតាំងថ្មីចំនួន៨រូបចូលជួបសម្តែងការគួរសម និងទទួលអនុសាសន៍



*សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា*

នាថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង៩ព្រឹក នៅវិមានព្រឹទ្ធសភា សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា បានអនុញ្ញាតឱ្យឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជាទើបតែងតាំងថ្មីចំនួន៨រូប ចូលជួបសម្តែងការគួរសម និងទទួលអនុសាសន៍ មុនអញ្ជើញចេញទៅបំពេញបេសកកម្មការទូតនៅបរទេស។

ឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជាទាំង៨រូប នោះរួមមាន៖

-ឯកឧត្តម **កុយ គួង** ឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសឥណ្ឌា

-ឯកឧត្តម **ហ៊ុន សារឿន** ឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសថៃឡង់ដ៍

-ឯកឧត្តម **ជីនបូរាណ ច័ន្ទបូរី** ឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសអូស្ត្រាលី

-ឯកឧត្តម **ជា ធីរៈ** ឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសគុយបា

-ឯកឧត្តម **ពេជ្រឃុន បញ្ញា** ឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសរុស្ស៊ី

-ឯកឧត្តម **ជុំ អឌ្ឍវិចិត្រ** ឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសមីយ៉ាន់ម៉ា

-ឯកឧត្តម **លឹម ហុកសេង** ឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសប្រ៊ុយណេ

-ឯកឧត្តម **អ៊ុក ចាន់ដារ៉ា** ឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសម៉ាឡេស៊ី។

នៅក្នុងឱកាសនោះ សម្តេចប្រធានព្រឹទ្ធសភាបានសម្តែងនូវការអបអរសាទរចំពោះឯកឧត្តមទាំង៨រូប ដែលត្រូវបានព្រះមហាក្សត្រទ្រង់សព្វព្រះរាជហឫទ័យតែងតាំងជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅបរទេស។ ជាមួយគ្នានោះ សម្តេច





*ឯកអគ្គរាជទូតកម្ពុជា ចូលជួបសម្តែងការគួរសម និងទទួលអនុសាសន៍ពីសម្តេចប្រធានព្រឹទ្ធសភា*




*ឯកអគ្គរាជទូតកម្ពុជា ចូលជួបសម្តែងការគួរសម និងទទួលអនុសាសន៍ពីសម្តេចប្រធានព្រឹទ្ធសភា*

បានផ្តាំផ្ញើចំពោះឯកឧត្តមទាំង៨រូបត្រូវយកចិត្តទុកដាក់ពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការឱ្យបានល្អ ដើម្បីផលប្រយោជន៍ទៅវិញទៅមករវាងព្រះរាជណាចក្រកម្ពុជា និងប្រទេសដែលខ្លួនតាំងនៅទាំងពេលបច្ចុប្បន្ន និងតទៅអនាគតយូរអង្វែង។ ដើម្បីសម្រេចបំណងនេះ ត្រូវយកចិត្តទុកដាក់ទំនាក់ទំនងល្អជាមួយនឹងបណ្តាស្ថាប័ន និងជាមួយនឹងប្រជាជន នៃប្រទេសនីមួយៗឱ្យបានល្អប្រសើរ។ ទន្ទឹមនឹងនេះ ត្រូវក្តាប់ជាប់ និងគិតគូរដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋខ្មែរ ពលករខ្មែរ ដែលកំពុងរស់នៅប្រកបអាជីវកម្ម និងធ្វើការងារនៅប្រទេសដែលខ្លួនត្រូវបំពេញភារកិច្ច។ ទោះបីស្ថិតក្នុងកាលៈទេសៈបែបណាក៏ដោយត្រូវបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយនឹងឯកអគ្គរាជទូត-រដ្ឋទូត នៃប្រទេសនានា ប្រចាំនៅប្រទេសដែលខ្លួនតាំងនៅ។

សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** បានផ្តល់អនុសាសន៍សំខាន់ៗមួយចំនួនជូនដល់ ឯកឧត្តមឯកអគ្គរាជទូតទាំងអស់ត្រូវសកម្មក្នុងការផ្សព្វផ្សាយ និងបកស្រាយពន្យល់អំពីសភាពការណ៍ពិត និងការអនុវត្តនូវលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាជូនដល់សាធារណមតិជាតិ និងអន្តរជាតិ ជាពិសេសនៅប្រទេសដែលកំពុងបំពេញភារកិច្ច។ ត្រូវផ្តល់ព័ត៌មានឱ្យបានរហ័សចំពោះសភាពការណ៍ជាក់ស្តែងរបស់កម្ពុជា និងត្រូវយកចិត្តទុកដាក់ផ្សព្វផ្សាយក្នុងការទាក់ទាញវិនិយោគិន និងភ្ញៀវទេសចរមកកម្ពុជាឱ្យបានកាន់តែច្រើន ព្រមទាំងផ្សព្វផ្សាយអំពីវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ដ៏ល្អរបស់កម្ពុជា។

ឯកឧត្តម **ភុយ ឃួន** តំណាងឯកអគ្គរាជទូតទាំងអស់បានប្តេជ្ញានៅចំពោះមុខសម្តេចប្រធានព្រឹទ្ធសភាថា នឹងខិតខំបំពេញភារកិច្ចការទូតដោយស័ក្តិសមជាតំណាងឱ្យព្រះរាជាណាចក្រកម្ពុជា នៅលើឆាកអន្តរជាតិ។

ឯកឧត្តមឯកអគ្គរាជទូតទាំងអស់បានសន្យាថា នឹងខិតខំអនុវត្តតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចប្រធានព្រឹទ្ធសភា និងខិតខំថែរក្សាការផ្សព្វផ្សាយអំពីប្រទេសជាតិ ពង្រឹងពង្រីកទំនាក់ទំនងសហប្រតិបត្តិការល្អប្រសើរជាមួយនឹងប្រទេសម្ចាស់ផ្ទះ និងឯកអគ្គរាជទូត-រដ្ឋទូតប្រទេសផ្សេងៗទៀត។ ព្រមទាំងខិតខំទាក់ទាញវិនិយោគិន និងអ្នកទេសចរឱ្យមកបណ្តាក់ទុន និងទស្សនានៅព្រះរាជាណាចក្រកម្ពុជាបានកាន់តែច្រើន ដើម្បីរួមចំណែកអភិវឌ្ឍប្រទេសជាតិ និងលើកកម្ពស់កិត្យានុភាពនៅក្នុងតំបន់ និងលើពិភពលោក៕

(អត្ថបទ៖រ៉ាន់ ពិសិដ្ឋ រូបភាព៖ គង់ យ៉ារីន)

# គណៈកម្មការទី៧ព្រឹទ្ធសភាចុះឈ្វេងយល់ អំពីវឌ្ឍនភាពការងាររបស់រាជបណ្ឌិត្យសភាកម្ពុជា



*ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា*

នាព្រឹកថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ នៃព្រឹទ្ធសភា (គណៈកម្មការទី៧) ដឹកនាំដោយ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ឌឹមហ៊ុយ** ប្រធានគណៈកម្មការ បានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងរាជបណ្ឌិត្យសភាកម្ពុជា ដឹកនាំដោយ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ដើម្បីឈ្វេងយល់ អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម និងទិសដៅការងារបន្តរបស់រាជបណ្ឌិត្យសភាកម្ពុជា ស្ថិតនៅសាលប្រជុំទន្លេសាប នៃរាជបណ្ឌិត្យសភាកម្ពុជា រាជធានីភ្នំពេញ។

ក្នុងនាមគណៈកម្មការទី៧ព្រឹទ្ធសភា ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ឌឹមហ៊ុយ** បានសម្តែងនូវមនោសញ្ចេតនាសោមនស្សរីករាយ ដែលបានមកទស្សនកិច្ចជាលើកទី២ នៅរាជបណ្ឌិត្យសភាកម្ពុជា។ តាមរយៈជំនួបនាពេលនោះ ពិតជាមានសារៈសំខាន់ណាស់ចំពោះគណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា ដើម្បីបានឈ្វេងយល់អំពីបេសកកម្ម រចនាសម្ព័ន្ធ ការប្រព្រឹត្តទៅ នៃការដ្ឋានសំខាន់ៗ សមិទ្ធផល បញ្ហាប្រឈម ដំណោះស្រាយ និងទិសដៅការងារបន្ត ព្រមទាំងការងារពាក់ព័ន្ធនឹងវិស័យគណៈកម្មការទី៧ព្រឹទ្ធសភា។

ក្នុងឱកាសនោះ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា បានសម្តែងនូវការស្វាគមន៍ និងធ្វើសេចក្តីរាយការណ៍ជម្រាបជូនគណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភាជ្រាបអំពី តួនាទី ភារកិច្ច រចនាសម្ព័ន្ធ សមិទ្ធផលនានារបស់រាជបណ្ឌិត្យសភាកម្ពុជាពីឆ្នាំ២០១៧ រហូតមកដល់បច្ចុប្បន្ន ព្រមទាំងបញ្ហាប្រឈម ដំណោះស្រាយ ទិសដៅការងារបន្ត និងគម្រោងសិក្សាស្រាវជ្រាវនាពេលកន្លងទៅដូចជា៖ គម្រោងព្រំដែនវៀតណាម និងឡាវ គម្រោងមីក្រូហិរញ្ញវត្ថុ គម្រោងទេសចរណ៍ គម្រោងសក្តានុពលបឹងទន្លេសាប។ គម្រោងកំពុងបន្តមានដូចជា៖ គម្រោងទឹកដោះគោ គម្រោងសាច់ពពែ ចៀម និងការអភិរក្សពូជក្របី គម្រោងចម្លាក់អប្សរា ម៉ូដសក់ សម្លៀកបំពាក់ និង





*គណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា ពិភាក្សាការងារជាមួយថ្នាក់ដឹកនាំរាជបណ្ឌិត្យសភាកម្ពុជា*



*ទិដ្ឋភាពរួមក្នុងជំនួបពិភាក្សាការងារ*

គ្រឿងលម្អកាយ គម្រោង App តំបន់ទេសចរណ៍កម្ពុជា គម្រោងវចនានុក្រមខ្មែរបុរាណ គម្រោងប្រវត្តិសាស្ត្រប្រទេសកម្ពុជា គម្រោងកិច្ចពិភាក្សាតុមូល និងគម្រោងតម្រូវការអាហារនៅកម្ពុជា។

បន្ទាប់ពីបានស្តាប់សេចក្តីរាយការណ៍ដ៏មានសារៈសំខាន់ និងកិច្ចពិភាក្សាគ្នាយ៉ាងផុលផុសដោយស្មារីទទួលខុសត្រូវ តម្កល់ផលប្រយោជន៍ជាតិជាធំរួចមក ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** បានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ ចំពោះវឌ្ឍនភាពការងាររបស់រាជបណ្ឌិត្យសភាកម្ពុជា ដែលសម្រេចបានគួរឱ្យកត់សម្គាល់។ ជាមួយគ្នានោះ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិតបានលើកទឹកចិត្តដល់រាជបណ្ឌិត្យសភាកម្ពុជា បន្តធ្វើសកម្មភាពដោយមានការប្តេជ្ញាចិត្តខ្ពស់ ដើម្បីរក្សាកិត្តិយស និងកិត្យានុភាពនៃស្ថាប័នជាតិ ត្រូវចេះជ្រើសរើសការងារអាទិភាព។

ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** សង្ឃឹមថា នាពេលអនាគតនឹងមានសៀវភៅសម្រាប់មនុស្សទូទៅមើល ដែលពាក់ព័ន្ធនឹងកម្ពុជា និងសៀវភៅយល់ដឹងអំពីព្រះពុទ្ធសាសនា សៀវភៅទាំងពីរនេះនឹងរួមចំណែកក្នុងការបណ្តុះបណ្តាលកូនខ្មែរក្នុងសម័យអន្តរកាល។ ដោយស្ថានភាពសកលលោកមានភាពស្មុគស្មាញយ៉ាងខ្លាំង ដោយវិបត្តិ នៃសង្គ្រាម វិបត្តិសុខភាពសាធារណៈ ការប្រែប្រួលអាកាសធាតុ។ ជាស្ថាប័នស្រាវជ្រាវត្រូវពង្រឹងសមត្ថភាពគ្រប់ពេល កុំមានគំនិតគ្រប់គ្រាន់និយម និងសូមជូនពរឱ្យរាជបណ្ឌិត្យសភាកម្ពុជា ទទួលបានជោគជ័យថ្មីៗបន្ថែមទៀត៕

(អត្ថបទ និងរូបភាព៖ លោក វង់ សុជាតិ)



*ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ម៉ុម ជឹមហ៊ុយ ជូនវត្ថុអនុស្សាវរីយ៍ដល់ថ្នាក់ដឹកនាំរាជបណ្ឌិត្យសភាកម្ពុជា*

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ អញ្ជើញឈ្វេងយល់ និងប្រមូលព័ត៌មាននៅមូលដ្ឋានចំនួន៥ខណ្ឌ ដើម្បីរៀបចំវេទិកា





*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ប្រជុំពិភាក្សាការងារជាមួយអាជ្ញាធរខណ្ឌដង្កោ*

ចាប់ពីថ្ងៃទី៩ ដល់ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ (រាជធានីភ្នំពេញ) ដឹកនាំដោយឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជា ចេដ្ឋ** ប្រធានក្រុម និងជាប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារដាច់ដោយឡែកពីគ្នាជាមួយនឹងអាជ្ញាធរ និងក្រុមប្រឹក្សាសង្កាត់ ចំនួន៥ខណ្ឌ រួមមាន៖ ខណ្ឌដង្កោ ខណ្ឌកំបូល ខណ្ឌពោធិ៍សែនជ័យ ខណ្ឌសែនសុខ និង ខណ្ឌព្រែកព្នៅ នៃរាជធានីភ្នំពេញ។

គោលបំណងនៃជំនួបពិភាក្សានោះ គឺដើម្បីឈ្វេងយល់ និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងការអភិវឌ្ឍមូលដ្ឋានសង្កាត់ ខណ្ឌ ជាពិសេសការងារភូមិ សង្កាត់មានសុវត្ថិភាព ការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ការងារជំរុញយុវជន យុវនារី នៅថ្នាក់ខណ្ឌ ការគ្រប់គ្រងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយផ្ដោតសំខាន់លើការលំបាក បញ្ហាសេសសល់ និងសំណូមពរ ដើម្បីឆ្ពោះទៅការរៀបចំវេទិកាភូមិភាគទី១ នាពេលខាងមុខ។

តាមរយៈការចូលរួមមតិយោបល់ជាមួយនឹងបញ្ហាទាំង-ឡាយដែលបានលើកឡើង ក្នុងកិច្ចពិភាក្សាតាមខណ្ឌនីមួយៗ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជា ចេដ្ឋ** បានថ្លែងនូវការកោតសរសើរ និងអបអរសាទរ ចំពោះអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដែលបានសហការគ្នាយ៉ាងល្អប្រសើររវាងក្រុម-ប្រឹក្សាសង្កាត់ នគរបាលប៉ុស្តិ៍រដ្ឋបាល និងប្រជាការពារដែលសម្រេចបានលទ្ធផលជាផ្លែផ្កា។ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត បានវាយតម្លៃខ្ពស់ចំពោះមតិយោបល់ទាំងឡាយ ដែលជាការចូលរួមចំណែកចែករំលែកនូវព័ត៌មាន និងបទពិសោធន៍ ដែលថ្នាក់មូលដ្ឋានបាន និងកំពុងអនុវត្ត ដោយទទួលបានទាំងលទ្ធផលវិជ្ជមាន និងអវិជ្ជមាន។



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១*
*ប្រជុំពិភាក្សាការងារជាមួយអាជ្ញាធរខណ្ឌកំបូល*



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១*
*អញ្ជើញថតរូបអនុស្សាវរីយ៍ជាមួយអាជ្ញធរខណ្ឌកំបូល*




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ប្រជុំពិភាក្សាការងារជាមួយអាជ្ញាធរខណ្ឌពោធិ៍សែនជ័យ*

ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជា ចេដ្ឋ** បានសង្កត់ធ្ងន់ថា អ្វីជាលទ្ធផលវិជ្ជមាន សូមអាជ្ញាធរមូលដ្ឋាន ត្រូវបន្តធ្វើឱ្យកាន់តែប្រសើរជាងនេះថែមទៀត។ ដោយឡែក អ្វីដែលជាការលំបាក និងការប្រឈមនឹងការអនុវត្តការងារ សូមអាជ្ញាធរគ្រប់លំដាប់ថ្នាក់សហការគ្នាផ្តល់ព័ត៌មានទៅវិញ-ទៅមក និងរួមគ្នាស្វែងរកវិធីដោះស្រាយ ធ្វើយ៉ាងណាឱ្យមូលដ្ឋាន ភូមិ សង្កាត់មានការវិវឌ្ឍទៅមុខ។

ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជា ចេដ្ឋ** បានបញ្ជាក់ថា នាពេលខាងមុខ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ នឹងរៀបចំវេទិការួមមួយ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងឡាយដែលអាជ្ញាធរមូលដ្ឋាន ភូមិ សង្កាត់បានលើកឡើង ដើម្បីរួមគ្នាឆ្លុះបញ្ចាំងនូវលទ្ធផលដែលបានអនុវត្តនាពេលកន្លងទៅ និងអនុវត្តកម្មវិធីអភិវឌ្ឍន៍ស្របទៅតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ (គ.ជ.អ.ប) តាមដំណាក់កាលថ្មី នៃការអភិវឌ្ឍមូលដ្ឋានសង្កាត់ឆ្នាំ២០២២-២០២៣៕

(អត្ថបទ និងរូបភាព៖ លោក គឹម សិទ្ធី)




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ប្រជុំពិភាក្សាការងារជាមួយអាជ្ញាធរខណ្ឌសែនសុខ*




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ប្រជុំពិភាក្សាការងារជាមួយអាជ្ញាធរខណ្ឌព្រែកព្នៅ*

# គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា

❈ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំ៖



-គណៈកម្មការទី១ព្រឹទ្ធសភា ដើម្បីពិនិត្យលើរបាយការណ៍ប្រចាំឆ្នាំ២០២២ របាយការណ៍អំពីថវិកា ការបែងចែកឧបករណ៍តេស្តរហ័ស និងបញ្ហាផ្សេងៗ នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា នាថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣។



-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ជាមួយនឹងមន្ត្រី ដើម្បីពិនិត្យពិភាក្សាលើរបាយការណ៍លទ្ធផលការងាររបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ប្រចាំឆ្នាំ២០២២ របាយការណ៍ថវិការបស់ក្រុម និងបញ្ហាផ្សេងៗ នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា នាថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣។

-ជាមួយនឹងមន្ត្រីជំនួយការគណៈកម្មការទី១ព្រឹទ្ធសភា និងមន្ត្រីការិយាល័យអមក្រុមភូមិភាគទី៨ ដើម្បីពិនិត្យ និងកែសម្រួលបញ្ចប់របាយការណ៍លទ្ធផលការងារប្រចាំឆ្នាំ២០២២ របស់គណៈកម្មការទី១ព្រឹទ្ធសភា និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា នាព្រឹកថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣។

❈ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជា ចេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបាន៖




-អនុញ្ញាតឱ្យថ្នាក់ដឹកនាំនៃក្រុមហ៊ុនផារ៉ាហ្គូន និងសាកលវិទ្យាល័យអន្តរជាតិផារ៉ាហ្គូន ដឹកនាំដោយលោក **ដាមៀរ-មូរ៉ាសែវ** (Mr. Damir Musaev) នាយកប្រតិបត្តិក្រុមហ៊ុនផារ៉ាហ្គូន ចូលជួបសម្ដែងការគួរសម និងជូនពរ ក្នុងឱកាសបុណ្យចូលឆ្នាំសកល ២០២៣ នៅសាលប្រជុំគណៈកម្មការទី២ព្រឹទ្ធសភា នាព្រឹកថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២។



-អញ្ជើញដឹកនាំកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ដើម្បីត្រៀមរៀបចំវេទិការវាងក្រុមសមាជិក

ព្រឹទ្ធសភាប្រចាំភូមិភាគទី១ ជាមួយនឹងក្រុមប្រឹក្សាសង្កាត់ទាំង១៤ខណ្ឌ ចំណុះសាលារាជធានីភ្នំពេញ ក្រោមប្រធានបទ "ការអភិវឌ្ឍមូលដ្ឋាន និងបម្រើសេវាជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព ធានាបានសុខសន្តិភាព" នៅសាលប្រជុំគណៈកម្មការទី២ព្រឹទ្ធសភា នាព្រឹកថ្ងៃទី៣ ខែមករា ឆ្នាំ២០២៣។



-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការទី២ព្រឹទ្ធសភា នាថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣ ដើម្បីត្រៀមចុះបំពេញបេសកកម្មសិក្សាឈ្វេងយល់អំពី "ការអភិវឌ្ឍមូលដ្ឋាន និងបម្រើសេវាជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព ធានាបានសុខសន្តិភាព" នៅខេត្តតាកែវ ដែលគ្រោងនឹងប្រព្រឹត្តទៅនៅដើមខែកុម្ភៈ ឆ្នាំ២០២៣ ខាងមុខនេះ។



-អញ្ជើញដឹកនាំកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ដើម្បីពិភាក្សាអំពីត្រៀមរៀបចំវេទិកាជាមួយនឹងក្រុមប្រឹក្សាសង្កាត់ ចំនួន៥ខណ្ឌ ក្នុងរាជធានីភ្នំពេញ នៅសាលប្រជុំគណៈកម្មការទី២ព្រឹទ្ធសភា នាព្រឹកថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣។

-អញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំគណៈកម្មការរៀបចំគ្រឿងឥស្សរិយយស ដើម្បីពិភាក្សាការងាររៀបចំគ្រឿងឥស្សរិយយសសម្រាប់បំពាក់ជូនសមាជិកព្រឹទ្ធសភា ចុង



នីតិកាលទី៤ នៅសាលប្រជុំពិសេស វិមានព្រឹទ្ធសភា នាព្រឹកថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៣។

❈លោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី ម៉ូវ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបាន៖



-អនុញ្ញាតឱ្យឯកឧត្តម Damien Regnard សមាជិកព្រឹទ្ធសភាបារាំង តំណាងឱ្យប្រជាពលរដ្ឋបារាំងនៅបរទេស និងជាសមាជិកគណៈកម្មការវប្បធម៌ អប់រំ និងទំនាក់ទំនងនៃព្រឹទ្ធសភាបារាំង ចូលជួបពិភាក្សាការងារក្នុងឱកាសដែលឯកឧត្តមអញ្ជើញមកបំពេញទស្សនកិច្ចការងារនៅព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នជាន់ខ្ពស់ នៃប្រទេសទាំងពីរកម្ពុជា-បារាំង ដើម្បីផ្លាស់ប្តូរព័ត៌មាន និងលើកកម្ពស់ភាសាបារាំង នៅសាលប្រជុំគណៈកម្មការទី៥ព្រឹទ្ធសភា នាថ្ងៃទី១២ ខែមករា ឆ្នាំ២០២៣។

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការទី៥ព្រឹទ្ធសភា នៅសាលប្រជុំគណៈកម្មការទី៥ព្រឹទ្ធសភា នាព្រឹកថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ ដើម្បីពិនិត្យ ពិភាក្សាលើ៖

១-ការបូកសរុបលទ្ធផលសកម្មភាពការងារគណៈកម្មការទី៥ព្រឹទ្ធសភាប្រចាំខែមករា ចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣



២-ពិនិត្យកែសម្រួលផែនការប្រតិបត្តិត្រីមាសទី១ ឆ្នាំ២០២៣ ដើម្បីត្រៀមជួបសវនាការជាមួយនឹងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ ត្រៀមជួបសវនាការជាមួយនឹងក្រសួងព័ត៌មាន និងត្រៀមជួបសវនាការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

៣-បិទបញ្ជីចំណូល-ចំណាយថវិការបស់គណៈកម្មការទី៥ព្រឹទ្ធសភា ឆ្នាំ២០២២

៤-បញ្ហាផ្សេងៗ។



❋នាថ្ងៃទី៩ និងថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំគណៈកម្មការពិសេសដើម្បីពិនិត្យ ពិភាក្សាលើសេចក្តីព្រាងស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅសាលប្រជុំពិសេស វិមានព្រឹទ្ធសភា។

❋ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖

-ដឹកនាំកិច្ចប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា ដើម្បីត្រៀមកិច្ចការសំខាន់ៗចំពោះមុខ ក្នុងដំណើរចុះឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម និងទិសដៅបន្តរបស់



រាជបណ្ឌិត្យសភាកម្ពុជា និងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ស្ថិតនៅសាលប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា នាថ្ងៃទី៩ ខែមករា ឆ្នាំ២០២៣។

-ស្តាប់បទបង្ហាញរបស់តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ លើករណីលិខិតអន្តរាគមន៍របស់ឯកឧត្តម **អ៊ុំ ទី** ប្រធានសហគមន៍គ្រីស្ទបរិស័ទគណៈនិកាយប្រូតេស្តង់កម្ពុជា នៅសាលប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា នាថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣។



❋នាព្រឹកថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំជាមួយនឹងក្រុមការងាររបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គី អភិវឌ្ឍន៍មាតុភូមិកម្ពុជា នៅសាលប្រជុំគណៈកម្មការទី៨ព្រឹទ្ធសភា។

❋ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបាន៖

-អនុញ្ញាតឱ្យលោកស្រី Jimin Jeong ប្រធានគ្រប់គ្រង G Foundation នៃអង្គការចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ និងសហការី ចូលជួបពិភាក្សាការងារស្តីពីការគ្រប់គ្រង និងប្រើប្រាស់អំណោយមនុស្សធម៌របស់អង្គការចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋ-



កូរ៉េ និងគម្រោងកិច្ចសហប្រតិបត្តិការបន្ត នៅសាលប្រជុំ-គណៈកម្មការទី១០ព្រឹទ្ធសភា នាថ្ងៃទី១៩ ខែមករា ឆ្នាំ ២០២៣។



ឈ្វេងយល់ពីវឌ្ឍនភាពការងារ រចនាសម្ព័ន្ធ បទពិសោធន៍ បញ្ហាប្រឈម និងចក្ខុវិស័យទៅមុខរបស់រាជបណ្ឌិត្យសភា នៅសាលប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា។



-ដឹកនាំកិច្ចប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា ដើម្បីពិនិត្យឆ្លងរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងារ និងរបាយការណ៍ថវិការបស់គណៈកម្មការប្រចាំខែមករា ឆ្នាំ២០២៣ ស្ថិតនៅសាលប្រជុំគណៈកម្មការទី១០ព្រឹទ្ធ-សភា នាព្រឹកថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣។

❈នាថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញដឹកនាំប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា ដើម្បីពិនិត្យ និងកែសម្រួលខ្លឹមសាររបាយការណ៍ស្តីពី លទ្ធផលជួបសវនាការ



❈នាព្រឹកថ្ងៃទី៥ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **ឆាយ ថណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំមន្ត្រីការិយាល័យអមក្រុមភូមិភាគទី២ ដើម្បីពិនិត្យរបាយការណ៍សកម្មភាពរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ និងរៀបចំផែនការសកម្មភាពចុះជួបប្រាស្រ័យទាក់ទងជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេលចន្លោះសម័យប្រជុំព្រឹទ្ធសភា នៅសាលប្រជុំគណៈកម្មការទី៦ព្រឹទ្ធសភា៕

## សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស

❈ចាប់ពីថ្ងៃទី៦ ដល់ថ្ងៃទី១២ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **ឈិត គឹមយាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញចូលរួមប្រជុំក្រុមប្រឹក្សាប្រតិបត្តិ និងមហាសន្និបាតលើកទី១៣ របស់សភាតំបន់អាស៊ី (APA) នៅទីក្រុងអានតាលីយ៉ា ប្រទេសតួកគី៕



# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨

❈នាព្រឹកថ្ងៃទី២ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា និងឯកឧត្តម **ញ៉ែម សាម៉ន** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបើកការដ្ឋានសាងសង់ស្ពានឆ្លងកាត់ទន្លេមេគង្គពីស្រុកចិត្របុរី ទៅស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិតាលុស ឃុំបុសលាវ ស្រុកចិត្របុរី ខេត្តក្រចេះ។

❈នាព្រឹកថ្ងៃទី៥ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីកាត់ឫសសីមា និងសម្ពោធសមិទ្ធផលនានា នៅក្នុងវត្តឧត្តមសាមគ្គី នៅភូមិវាលកន្សែង ឃុំកំពង់ដំរី ស្រុកឆ្លូង ខេត្តក្រចេះ ក្រោមអធិបតីភាពឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក។

❈ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋដែលអញ្ជើញមកទស្សនាសួនសត្វ ព្រមទាំងដឹកនាំក្រុមការងារគ្រឿងចក្រសាងសង់សហចេតិយ រោងបុណ្យ និងកែលម្អសួនសត្វឱ្យមានសោភ័ណភាព ព្រមទាំងផាសុកភាពសត្វប្រសើរឡើងវិញ ដើម្បីទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិចូលទស្សនាកម្សាន្ត នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២។

-ចូលរួមជាមួយកម្មករ និងប្រជាពលរដ្ឋប្រលែងត្រីគល់រាំងជាត្រីតំណាងជាតិ ជាលើកទី៣ ចំនួន២០ក្បាល នៅតំបន់អភិវឌ្ឍន៍ម៉ុង ឫទ្ធីសែនជ័យ ដើម្បីរក្សាទុកសម្រាប់ភ្ញៀវជាតិ និងអន្តរជាតិទស្សនាកម្សាន្ត ព្រមទាំងទទួលជួបប្រជាពលរដ្ឋអញ្ជើញមកពីសហរដ្ឋអាមេរិកដែលអញ្ជើញមកទស្សនាសួនសត្វ សហចេតិយ រោងបុណ្យ ប្រាសាទ ព្រះវិហារ និងហេដ្ឋារចនាសម្ព័ន្ធនានា នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២។

-ជួបសំណេះសំណាល សួរសុខទុក្ខកម្មករ និងពិនិត្យមើលក្រុមការងារគ្រឿងចក្រឈូសឆាយសម្អាតដី ដើម្បីត្រៀមដាំដើមក្រូចថ្លុងចំនួន១២ហិកតា ស្មើនឹង៤.៨០០ដើម ដើមដូងក្រអូបចំនួន២២ហិកតា ស្មើនឹង៦.២០០ដើម រៀបចំហេដ្ឋារចនាសម្ព័ន្ធផ្លូវ ព្រមទាំងចូលរួមជាមួយនឹងកម្មករប្រជាពលរដ្ឋប្រលែងត្រីគល់រាំងជាត្រីតំណាងជាតិ និងត្រីប្រា ជាលើកទី៤ នៅក្នុងតំបន់រមណីយដ្ឋានអភិវឌ្ឍន៍កសិទេសចរណ៍ ម៉ុង ឫទ្ធីសែនជ័យ ដើម្បីរក្សាទុកសម្រាប់ភ្ញៀវជាតិ និងអន្តរជាតិទស្សនាកម្សាន្ត នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។



-ជាអធិបតីភាពក្នុងពិធីសំណេះសំណាល និងចែករង្វាន់លើកទឹកចិត្តដល់សិស្សជ័យលាភី ក្នុងការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡងថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២២ និងលោកគ្រូ អ្នកគ្រូបង្រៀនសិស្សថ្នាក់ទី១២ នៃវិទ្យាល័យក្នុងខេត្តព្រះសីហនុ ក្រោមអធិបតីភាពឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាថ្ងៃទី៣ ខែមករា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងដឹកនាំក្រុមការងារផ្នែកកសិកម្មចុះពិនិត្យរៀបចំឈូសឆាយសម្អាតដីចំនួន២២ហិកតា ដើម្បីដាំដើមដូងក្រអូបចំនួន៦.២០០ដើម នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៦ ខែមករា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យមើលចម្ការឪឡឹក និងបង្ហាត់បង្រៀនពួកគាត់អំពីការថែទាំដំណាំផ្សេងៗ នៅភ្នំសែនជ័យ ស្រុកសំរោងទង



ខេត្តកំពង់ស្ពឺ នាថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៣។

-ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ចុះទៅព្យាបាលជំងឺជូនប្រជាពលរដ្ឋចំនួន៤០០នាក់ មកទទួលព្យាបាលភ្នែកដោយឥតគិតថ្លៃ នៅតំបន់អភិវឌ្ឍន៍កសិទេសចរណ៍ ម៉ុង ឫទ្ធី-សែនជ័យ ភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣។

-ចូលរួមជាមួយនឹងកម្មករ និងប្រជាពលរដ្ឋប្រលែងត្រីគល់រាំងជាត្រីតំណាងជាតិ ត្រីប្រា និងត្រីត្រសក់ នៅក្នុងតំបន់រមណីយដ្ឋានអភិវឌ្ឍន៍កសិទេសចរណ៍ ម៉ុង ឫទ្ធី សែន-ជ័យដើម្បីរក្សាទុកសម្រាប់ភ្ញៀវជាតិ និងអន្តរជាតិទស្សនាកម្សាន្តនៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល សួរសុខទុក្ខកម្មករ ប្រជាពល-រដ្ឋអញ្ជើញមកសម្រាកកម្សាន្ត ព្រមទាំងទស្សនាសួនសត្វនៅតំបន់អភិវឌ្ឍន៍កសិទេសចរណ៍ម៉ុង ឫទ្ធីសែនជ័យ ព្រម-ទាំងចុះពិនិត្យមើលសកម្មភាពការងាររៀបចំផ្សាំកូនដូងក្រអូបចំនួន១២.០០០ដើម និងចុះពិនិត្យមើលការផលិតជីធម្មជាតិ នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២១ ខែមករា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋមកទស្សនាសហចេតិយដែលអាចតម្កល់ធាតុប្រមាណជា២០០០កោដ្ឋ ដែលបានស្ថាបនាជិតរួចរាល់ជាស្ថាពរ នៅតំបន់អភិវឌ្ឍន៍កសិទេសចរណ៍ម៉ុង ឫទ្ធី សែនជ័យ ភ្នំសែន-ជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២២ ខែមករា ឆ្នាំ២០២៣។

-ទទួលជួបភ្ញៀវជនជាតិចិនចំនួន១៣នាក់ដែលមកទស្សនកិច្ចសិក្សាឈ្វេងយល់ និងទស្សនាហេដ្ឋារចនាសម្ព័ន្ធនានា នៅតំបន់អភិវឌ្ឍន៍កសិទេសចរណ៍ ម៉ុង ឫទ្ធី សែន-ជ័យ នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៣។

❋នាថ្ងៃទី៨ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះ-សំណាលជាមួយនឹងប្រជាពលរដ្ឋ ក្នុងឱកាសអបអរខួបអនុស្សាវរីយ៍លើកទី៤៤ ឆ្នាំ (៧ មករា ១៩៧៩-៧ មករា ២០២៣) នៃទិវាជ័យជម្នះ ៧មករា នៅឃុំព្រៃស្នៀត ខេត្តព្រៃវែង។



❋នាថ្ងៃទី៤ ខែមករា ឆ្នាំ២០២៣ លោកជំទាវកិត្តិនីតិ-កោសលបណ្ឌិត **ទី ប៉ូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធ-សភាបានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខ និងជូនពរក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល២០២៣ ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ព្រមទាំងនាំយកនូវថ្នាំពេទ្យ និងបរិក្ខារពេទ្យមួយចំនួន រួមមាន៖ ថ្នាំ KAL-CEE ចំនួន៦៦ទីប ថ្នាំSanaflu ចំនួន១.០៤០គ្រាប់ ថ្នាំIODINEចំនួន១២០ដប ថ្នាំLIANHUA QINGWEN JIAONANGចំនួន១៨ប្រអប់ ឧបករណ៍តេស្តរហ័សចំនួន១.៣៥០តេស្ត អាវលោកយាយចំនួន៥០អាវ ទឹកត្រចៀកកាំចំនួន២៤ដប និងថវិកាមួយចំនួន ជូនអាជ្ញាធរស្រុកពញាឮ នៅសាលាស្រុកពញាឮ ខេត្តកណ្ដាល។

❋នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះ-សំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ ដើម្បីឈ្វេងយល់ការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ និងការផ្តល់សេវា-សាធារណៈជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន នៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

❋នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីបើកការដ្ឋានស្ថារ និងលើកកម្រិតគុណភាពផ្លូវជាតិលេខ៤១ ប្រវែងសរុប៩៥,២៧ គីឡូម៉ែត្រ ចាប់ពីថ្នល់ទទឹង (ចំណុច




ប្រសព្វផ្លូវជាតិលេខ៤) ដល់ជុំគិរី ខេត្តកំពត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិចាស់ ឃុំព្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។

❈ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាសង្កាត់ នគរបាលរដ្ឋបាលប៉ុស្តិ៍សង្កាត់ភ្លើងឆេះរទេះ និងសង្កាត់ប្រទះឡាង ព្រមទាំងឧបត្ថម្ភឧបករណ៍តេស្តរហ័សមួយកេសធំ និងថវិកាមួយចំនួន នៅខណ្ឌកំបូល រាជធានីភ្នំពេញ នាថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២។



-ជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាសង្កាត់គោករកា ខណ្ឌព្រែកព្នៅ សង្កាត់ត្រពាំងក្រសាំង និងសង្កាត់ចោមចៅ ព្រមទាំងឧបត្ថម្ភឧបករណ៍តេស្តរហ័ស និងថវិកាមួយចំនួន នៅខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ នាថ្ងៃទី៤ ខែមករា ឆ្នាំ២០២៣។



-ជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាសង្កាត់ស្នោរ ព្រមទាំងឧបត្ថម្ភឧបករណ៍តេស្តរហ័សនិងថវិកាមួយចំនួន នៅខណ្ឌកំបូល រាជធានីភ្នំពេញ នាថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៣។



-ជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាសង្កាត់ នគរបាលប៉ុស្តិ៍រដ្ឋបាល សង្កាត់ឪឡោក ព្រមទាំងឧបត្ថម្ភឧបករណ៍តេស្តរហ័ស និងថវិកាមួយចំនួន នៅខណ្ឌកំបូល រាជធានីភ្នំពេញ នាថ្ងៃទី២១ ខែមករា ឆ្នាំ២០២៣។

❈នាព្រឹកថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋតាមខ្នងផ្ទះរស់នៅក្នុងឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង។

❈ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកអំណោយចែកជូនដល់ក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋក្នុងឃុំត្រពាំងវែង សរុបចំនួន៣០៣នាក់ រួមមាន៖ អាវកីឡាចំនួន១៧កេស ស្មើ៤០៨អាវ ខោកីឡា១១កេស ស្មើ៣៨ខោ សេរ៉ូមលាបមុខ១៨កេស ស្មើ១០៨ប្រអប់ ម៉ាស់បិទមុខ១៤កេស ស្មើ ៤៤៨ប្រអប់ ម្សៅទ្រនាប់លាបមុខ៤កេស ស្មើ១៧៦ប្រអប់



និងសារុងចំនួន១៤៥ ឧបត្ថម្ភថវិកាមួយចំនួន ព្រមទាំងចូល-រួមរំលែកទុក្ខ និងចូលបច្ច័យបុណ្យសពប្រជាពលរដ្ឋក្នុងឃុំ ចំនួន៧គ្រួសារ នៅសាលាឃុំត្រពាំងវែង ស្រុកកណ្ដាល-ស្ទឹង ខេត្តកណ្ដាល នារសៀលថ្ងៃទី១ ខែមករា ឆ្នាំ២០២៣។



-ជួបសំណេះសំណាលជាមួយនឹងអាជ្ញាធរភូមិ ឃុំ និង ប្រជាពលរដ្ឋសរុបជាង៣០០នាក់ ក្នុងឱកាសពិធីអបអរ-សាទរខួបអនុស្សាវរីយ៍លើកទី៤៤ ទិវាជ័យជម្នះ ៧ មករា នៅឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល នាព្រឹក ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៣។



-ជួបសំណេះសំណាលជាមួយនឹងអាជ្ញាធរភូមិ ឃុំ និង ប្រជាពលរដ្ឋសរុបជាង៣០០នាក់ ក្នុងឱកាសពិធីអបអរ-សាទរខួបអនុស្សាវរីយ៍លើកទី៤៤ ទិវាជ័យជម្នះ ៧ មករា នៅឃុំត្រពាំងវែង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល នា ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៣។

❋ឯកឧត្តម **ខៀវ មុត** អនុប្រធានគណៈកម្មការទី១ ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាឃុំ ដើម្បីស្វែងយល់អំពីការអនុវត្តការងារក្នុងការផ្ដល់សេវា សាធារណៈជូនប្រជាពលរដ្ឋក្នុងឃុំ បញ្ហាប្រឈម និង សំណូមពរនៅឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ នាថ្ងៃ ទី១ ខែមករា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល សួរសុខទុក្ខជាមួយនឹងថ្នាក់-ដឹកនាំខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ក្នុងឱកាសពិធីអបអរ-សាទរខួបអនុស្សាវរីយ៍លើកទី៤៤ ទិវាជ័យជម្នះ ៧ មករា ក្រោមអធិបតីភាពឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុក ទីស្ដីការគណៈរដ្ឋមន្ត្រី នៅក្រុងដូនកែវ ខេត្តតាកែវ នាថ្ងៃទី ៧ ខែមករា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងអាជ្ញាធរភូមិ ឃុំ និង ប្រជាពលរដ្ឋ នៅសាលាស្រុកត្រាំកក់ ខេត្តតាកែវ ព្រមទាំង នាំយកឧបករណ៍តេស្តរហ័សកូវីដ-១៩ ចំនួន១៤៤ប្រអប់ ស្មើនឹង៣.៦០០ឧបករណ៍តេស្តជូនដល់មណ្ឌលសុខភាព ចំនួន១៦មណ្ឌល ដែលក្នុងមួយមណ្ឌលទទួលបាន៩ប្រអប់ ស្មើនឹង១២៥ឧបករណ៍តេស្ត ក្នុងឱកាសពិធីអបអរសាទរ ខួបអនុស្សាវរីយ៍លើកទី៤៤ ទិវាជ័យជម្នះ ៧ មករា នាថ្ងៃទី ១៤ ខែមករា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ ស្មៀន ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនជូនដល់ការរៀបចំអង្គពិធី និងស្មៀន ឃុំ ដែលត្រូវបានចោរគាស់ផ្ទះលួចយកទ្រព្យ សម្បត្តិ ក្នុងឱកាសពិធីអបអរសាទរខួបអនុស្សាវរីយ៍លើក ទី៤៤ ទិវាជ័យជម្នះ ៧ មករា នៅសាលាឃុំតាភេម ស្រុក ត្រាំកក់ ខេត្តតាកែវ នាថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣។



❋នាថ្ងៃទី៥ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **ខៀវ មុត** អនុប្រធានគណៈកម្មការទី១ព្រឹទ្ធសភា និងឯកឧត្តម **ឆេព**

**ឃុន្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីសុខាភិបាលនៅតាមមណ្ឌលសុខភាពទាំងប្រាំនៅក្នុងខេត្តកែប ព្រមទាំងបាននាំយកឧបករណ៍តេស្តរហ័សកូវីដ-១៩ ចំនួន៤៥ប្រអប់ស្មើនឹងចំនួន១.១២៥តេស្ត ដោយក្នុងមួយមណ្ឌលសុខភាពទទួលបានចំនួន៩ប្រអប់ស្មើនឹង២២៥តេស្ត និងឧបត្ថម្ភថវិកាមួយចំនួនដល់ស្ត្រីម្នាក់ដែលមកសម្រាលកូន និងសម្រាកនៅមណ្ឌលសុខភាពចំការបី។



❉ឯកឧត្តម **ខៀវ មុត** អនុប្រធានគណៈកម្មការទី១ព្រឹទ្ធសភា លោកជំទាវ **ភង សៅរ៉ែធន** លេខាធិការគណៈ-កម្មការទី៣ព្រឹទ្ធសភា និងឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះ-សំណាលជាមួយនឹងមន្ត្រីសុខាភិបាលនៅតាមមណ្ឌលសុខភាពចំនួនប្រាំនៅក្នុងក្រុងកំពត និងក្រុងបូកគោ ខេត្តកំពត ព្រមទាំងនាំយកឧបករណ៍តេស្តរហ័សកូវីដ-១៩ ចំនួន៤៥ប្រអប់ស្មើនឹងចំនួន១.១២៥ឧបករណ៍ ដោយក្នុងមួយមណ្ឌលសុខភាពទទួលបានចំនួន៩ប្រអប់ស្មើនឹង២២៥ឧបករណ៍ នាថ្ងៃទី៦ ខែមករា ឆ្នាំ២០២៣។

❉ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងដោះស្រាយសំណូមពរផ្សេងៗរបស់ប្រជាពលរដ្ឋ នៅឃុំកោះរកា ស្រុកពាមជរ ខេត្តព្រៃវែង នាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២២។

-ជាអធិបតីក្នុងកិច្ចប្រជុំជាមួយនឹងអាជ្ញាធរឃុំឫស្សីស្រុក ព្រមទាំងឧបត្ថម្ភឧបករណ៍បំពងសំឡេង១គ្រឿង សៀវភៅចំនួន២០០ក្បាល ប៊ិច២០០ដើម ប្រដាប់ធ្វើតេស្តរហ័សចំនួន៤៤ប្រអប់ សៀវភៅនិទានុលេខន៍ព្រឹទ្ធសភាចំនួន១០ក្បាល ប្រតិទិនព្រឹទ្ធសភា១០ និងឧបត្ថម្ភថវិកាមួយចំនួនក្នុងការរៀបចំពិធីនៅស្រុកពាមជរ ខេត្តព្រៃវែង នាថ្ងៃទី៣១ខែធ្នូ ឆ្នាំ២០២២។

-ជួបសំណេះសំណាលប្រជាពលរដ្ឋ ក្នុងឱកាសពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៤ ទិវាជ័យជម្នះ ៧ មករា នៅវត្តព្រៃមាន់ ឃុំឫស្សីស្រុក ស្រុកពាមជរ ខេត្តព្រៃវែង នាថ្ងៃទី៧ ខែមករា ឆ្នាំ២០២៣។

❉នាថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **ចាន់ ណារ៉េត** អនុប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា និងឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីអបអរសាទរបុណ្យឆ្លងឆ្នាំសកល២០២៣ នៅមណ្ឌលក្ដីសង្ឃឹមអាស៊ី នៃអង្គការក្ដីសង្ឃឹមអាស៊ីអន្តរ-ជាតិ ភូមិអន្លង់វិល ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចក្រឡាហោម **ស ខេង** នាយករដ្ឋមន្ត្រីស្ដីទី នៃព្រះរាជាណាចក្រកម្ពុជា។

❉នាព្រឹកថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា ឯកឧត្តម **ថុង ចន់** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីសំណេះសំណាលប្រជាពលរដ្ឋ ក្នុងឱកាសអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៤ នៃទិវាជ័យជម្នះ៧មករា (៧ មករា ១៩៧៩ -៧ មករា ២០២៣) ព្រមទាំងចូលរួមពិធីកសាងទីលានផ្នូរអតីតយុទ្ធជន (បង្ហាញពីកតញ្ញ-តាធម៌ចំពោះអ្នកពលី) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៅខេត្តកោះកុង។

❉ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមប្រជុំជាមួយនឹងលោកស្រីប្រធានមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ និងសហការី ដើម្បីស្ដាប់របាយការណ៍ ស្ដីពីវឌ្ឍនភាពការងារឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣ នៅសាលប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា នាព្រឹកថ្ងៃទី៣០

ខែធ្នូ ឆ្នាំ២០២២។



-ចូលរួមប្រជុំជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រធានភូមិទាំង១៣ ដើម្បីវាយតម្លៃសមិទ្ធផលការងារសំខាន់ៗ ឆ្នាំ២០២២ បញ្ហាប្រឈមនានា និងទិសដៅសម្រាប់អនុវត្តឆ្នាំ២០២៣ ព្រមទាំងឧបត្ថម្ភឧបករណ៍តេស្តរហ័ស និងថវិកាប្រចាំខែរបស់សមាគមមនុស្សចាស់ នៅសាលាសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ នារសៀលថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២។



-ចូលរួមជាមួយនឹងអភិបាលខណ្ឌ ក្រុមប្រឹក្សាខណ្ឌ និងចៅសង្កាត់ទាំង១០ ដើម្បីពិនិត្យស្ថិតិប្រជាពលរដ្ឋមានប័ណ្ណសមធម៌កម្រិតក្រ១ និងកម្រិតក្រ២ និងប្រជាពលរដ្ឋងាយរងហានិភ័យអំឡុងពេលមានអតិផរណានៅតាមមូលដ្ឋានសង្កាត់ បម្រើឱ្យការអនុវត្តគោលនយោបាយឧបត្ថម្ភសាច់ប្រាក់បានត្រឹមត្រូវតាមគោលការណ៍ក្រសួងពាក់ព័ន្ធ ព្រម-ទាំងឧបត្ថម្ភឧបករណ៍តេស្តរហ័សមួយចំនួន នៅខណ្ឌទួលគោក រាជធានីភ្នំពេញ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។



-ជួបសំណេះសំណាលជាមួយនឹងមន្ត្រីលេខាធិការដ្ឋានអមគណៈកម្មការទី៦ និងទី៩ព្រឹទ្ធសភា ព្រមទាំងឧបត្ថម្ភសម្ភារសិក្សា និងកង់ចំនួន៤គ្រឿង ដល់កូនមន្ត្រី ដើម្បីចូលរួមអបអរសាទរបើកបវេសនកាលឆ្នាំ២០២២-២០២៣ នៅគណៈកម្មការទី៧ព្រឹទ្ធសភា នាព្រឹកថ្ងៃទី៤ ខែមករា ឆ្នាំ២០២៣។



-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាសង្កាត់ផ្សារដើមថ្កូវ ព្រមទាំងឧបត្ថម្ភឧបករណ៍តេស្តរហ័សមួយចំនួន នៅខណ្ឌចំការមន រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី៤ ខែមករា ឆ្នាំ២០២៣។



-ចូលរួមពិធីកាត់វិញ្ញាសា ដើម្បីបើកការប្រឡងធម្មវិន័យថ្នាក់ត្រី ទោ ឯក ឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាល័យសម្តេច ហ៊ុន សែន ភ្នំពេញថ្មី នាថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៣។

❋នាថ្ងៃទី៨ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា និងលោកជំទាវ **មុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចូលរួមជាមួយនឹងព្រះសិរីកោសល **សុំ សុខា** ព្រះ-រាជាគណៈថ្នាក់កិត្តិយស រៀបចំទេយ្យទាន សម្ភារមួយចំនួនរួមមាន៖ អង្ករ ភេសជ្ជៈ មី ត្រីខ ទឹកបរិសុទ្ធ ទឹកត្រី ទឹកស៊ីអ៊ីវ ទឹកដោះគោ ស្ករ-ស បាឡេង តៃ និងបច្ច័យជូនដល់មជ្ឈមណ្ឌលឱកាសខ្ញុំ ដើម្បីជួយដល់ជនរងគ្រោះដោយ



គ្រឿងញៀន នៅមជ្ឈមណ្ឌលឱកាសខ្ញុំ។

❈ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាលជាមួយនឹងអាជ្ញាធរ និងប្រជាពលរដ្ឋសរុបចំនួន៣២១នាក់ ក្នុងឱកាសអបអរសាទរខួបលើកទី៤៤ ថ្ងៃជ័យជម្នះ ៧មករា (៧ មករា ១៩៧៩- ៧ មករា ២០២៣) នៅឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្ដាល នាព្រឹកថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣។



-ជួបសំណេះសំណាល និងសួរសុខទុក្ខលោក **ណៃ ឡាយ** ជំទប់ទី១ ឃុំដំណាក់អំពិល និងលោក **ឆ្វ ចំណាច** ប្រធានភូមិរងថ្នល់ទទឹង ឃុំដំណាក់អំពិល ដែលកំពុងសម្រាកព្យាបាលជំងឺ នៅគេហដ្ឋានស្ថិតនៅឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្ដាល នាព្រឹកថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣។

❈ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២២ និងទិសដៅការងារបន្ត នៅខេត្តស្វាយរៀង នាថ្ងៃទី៨ ខែមករា ឆ្នាំ២០២៣។



❈នាព្រឹកថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា និង ឯកឧត្តម **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល និងពិភាក្សាការងារ ជាមួយនឹងក្រុមប្រឹក្សាឃុំ មន្ត្រីពាក់ព័ន្ធមួយចំនួនទៀត ស្ដីពីការងារឆ្ពោះទៅបោះឆ្នោតពេលខាងមុខ និងឧបត្ថម្ភដល់សិស្សប្រឡងជាប់សញ្ញាបត្រទុតិយភូមិនិទ្ទេស A នៅវិទ្យាល័យមិត្តភាពកម្ពុជា-វៀតណាមព្រះពន្លា រួមមាន៖ កុំព្យូទ័រចំនួន១គ្រឿង ថវិកាមួយចំនួន ព្រមទាំងជូនអាចារ្យវត្តព្រះពន្លា មានសៀវភៅ សម្ភារផ្សេងៗ ថវិកាមួយចំនួន និងឧបត្ថម្ភឧបករណ៍តេស្តរហ័សកូវីដ-១៩ ចំនួនពីរកេសធំជូនរដ្ឋបាលឃុំ នៅឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។

❈ឯកឧត្តម **ហែម ខន** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាកិត្តិយសក្នុងពិធីបើកការដ្ឋានសាងសង់ផ្លូវបេតុង ១ខ្សែ ប្រវែង៤.២០០ម៉ែត្រ ក្រោមអធិបតីភាពឯកឧត្តម **ហ៊ុន ម៉ានី** អ្នកតំណាងរាស្ត្រមណ្ឌលខេត្តកំពង់ស្ពឺ នៅឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៤ ខែមករា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងអាជ្ញាធរស្រុកសំរោងទង ដើម្បីរៀបចំបើកវគ្គបណ្ដុះបណ្ដាលដល់មន្ត្រីឃុំ និងភូមិ សរុបចំនួន៩៥នាក់ និងឧបត្ថម្ភថវិកាមួយចំនួន នៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៥ ខែមករា ឆ្នាំ២០២៣។

-ចូលរួមជាកិត្តិយសក្នុងពិធីជួបសំណេះសំណាលជាមួយនឹងគ្រូបង្រៀនចំនួន១.១៣៥នាក់ និងគ្រូពេទ្យចំនួន៩៤នាក់ ក្រោមអធិបតីភាពឯកឧត្តម **ហ៊ុន ម៉ានី** អ្នកតំណាងរាស្ត្រមណ្ឌលខេត្តកំពង់ស្ពឺ នៅក្នុងបរិវេណមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៨ ខែមករា ឆ្នាំ២០២៣។

-ចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរការប្រកាសភូមិចំនួន៤ ក្នុងស្រុកគងពិសី ជាភូមិអស់មីន ក្រោមអធិបតីភាពឯកឧត្តម **ហ៊ុន ម៉ានី** អ្នកតំណាងរាស្ត្រ មណ្ឌលខេត្តកំពង់ស្ពឺ នៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាស្រុកសំរោងទង ក្រុមប្រឹក្សាឃុំរលាំងគ្រើល ឃុំរលាំងចក និងឃុំសែនដី សរុបចំនួន៣០នាក់ ព្រមទាំងឧបត្ថម្ភអាហារសាមគ្គីចំនួន១ពេល ថវិកាមួយចំនួនដល់អាជ្ញាធរឃុំ ភូមិចំនួន២៥នាក់ និងឧបករណ៍ធ្វើតេស្តរហ័សរកមេរោគកូវីដ-១៩ ជូនថ្នាក់ស្រុក២ប្រអប់ និងឃុំទាំង៣ ដោយក្នុងមួយឃុំៗទទួលបាន១ប្រអប់ នៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣។

❈នាថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **ឈាំ ទុំ** លេខាធិការគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខដល់ក្រុមប្រឹក្សាឃុំ នៅឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។

❈នាថ្ងៃទី៧ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **គិន ណែត** លេខាធិការគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ក្នុងឱកាសអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៤ ទិវាជ័យជម្នះ ៧ មករា (៧ មករា ឆ្នាំ១៩៧៩- ៧ មករា ឆ្នាំ២០២៣) នៅមុខទីធ្លាសាលមហោស្រព ខេត្តតាកែវ។



❈នាព្រឹកថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ លោកជំទាវ **ភាង សៅរ៍ឆន** លេខាធិការគណៈកម្មការទី៣ព្រឹទ្ធសភាព្រឹទ្ធសភា ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា និងឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្ម-ការទី៨ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខមន្ត្រីបុគ្គលិកសុខាភិបាលស្រុកប្រតិបត្តិកំពង់-ត្រាច មណ្ឌលសុខភាពទាំង៩ ព្រមទាំងប្រគល់ឧបករណ៍តេស្តរហ័សកូវីដ-១៩ចំនួន៨១ប្រអប់ ស្មើនឹងឧបករណ៍តេស្តចំនួន២.០២៥ ដល់មណ្ឌលសុខភាពទាំង៩ ដោយក្នុងមួយមណ្ឌលសុខភាពទទួលបានចំនួន៩ប្រអប់ស្មើនឹង២២៥ឧបករណ៍ នៅភូមិកំពង់ត្រាចទី១ ឃុំកំពង់ត្រាច-ខាងកើត ស្រុកកំពង់ត្រាច ខេត្តកំពត។



❈នាថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ លោកជំទាវ **ភាង សៅរ៍ឆន** លេខាធិការគណៈកម្មការទី៣ព្រឹទ្ធសភា ឯក-ឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខមន្ត្រីបុគ្គលិកសុខាភិបាលស្រុកជុំគិរី មណ្ឌលសុខភាពទាំង៦ចំណុះ ព្រមទាំងប្រគល់ឧបករណ៍តេស្តរហ័សកូវីដ-១៩ ចំនួន៥៤ប្រអប់ស្មើនឹង១៣៥០ឧបករណ៍តេស្តដល់មណ្ឌលសុខភាពទាំង៦ ដោយក្នុងមួយមណ្ឌលសុខភាពទទួលបានចំនួន៩ប្រអប់ស្មើនឹង២២៥ឧបករណ៍តេស្ត ព្រមទាំងសួរសុខទុក្ខប្រជាពលរដ្ឋកំពុងសម្រាកព្យាបាលជំងឺ និងចែកថវិកាមួយចំនួន នៅមណ្ឌលសុខភាព ឃុំត្រពាំងរាំង ស្រុកជុំគិរី ខេត្តកំពត។

❈នាព្រឹកថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៣ លោកជំទាវ **ភាង សៅរ៍ឆន** លេខាធិការគណៈកម្មការទី៣ព្រឹទ្ធសភា និងឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា បានចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលជាមួយនឹងសិស្សជ័យលាភីប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ



ឆ្នាំសិក្សា២០២១-២០២២ ទូទាំងខេត្តកំពត នៅក្នុងពហុកីឡដ្ឋានខេត្តកំពត ក្រោមអធិបតីភាពឯកឧត្តម **ម៉ែន ស៊ីម៉ន** ប្រធានគណៈកម្មការទី១០នៃរដ្ឋសភា។

❋នាថ្ងៃទី៨ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **អន ស៊ុំ** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញចូលរួមជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ក្នុងឱកាសអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៤ (៧ មករា ១៩៧៩-៧ មករា ២០២៣) នៃទិវាជ័យជម្នះ ៧មករា ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

❋នាថ្ងៃទី៩ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **អន ស៊ុំ** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំត្រួតពិនិត្យការងារស្ដីពី ការអភិវឌ្ឍភូមិ សង្កាត់មានសុវត្ថិភាព និងការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋនៅមូលដ្ឋាន ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅសាលាខេត្តបន្ទាយមានជ័យ។

❋ឯកឧត្តម **ឆាយ ទណ្ណា** លេខាធិការគណៈកម្មការ



ទី៥ព្រឹទ្ធសភាបានអញ្ជើញជាអធិបតីភាពក្នុងពិធី៖

-បើកបវេសនកាលឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាល័យក្បាលអូរ ស្ថិតនៅឃុំគរ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នាថ្ងៃទី២ ខែមករា ឆ្នាំ២០២៣។



-បើកបវេសនកាលឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាល័យឥស្លាមព្រែកជ័រ ស្ថិតនៅភូមិព្រែកជ័រ ឃុំសេដា ស្រុកតំបែរ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣។



-បិទការប្រកួតកីឡាបាល់ទាត់ពានរង្វាន់របស់ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅទីលានបាល់ទាត់ក្នុងឃុំជំនីក ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣។

❋ឯកឧត្តម **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ក្នុងឱកាសអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៤ (៧ មករា ១៩៧៩-៧ មករា ២០២៣) នៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង នាថ្ងៃទី៧ ខែមករា ឆ្នាំ២០២៣។

-ចុះត្រួតពិនិត្យវឌ្ឍនភាព នៃការអនុវត្តផែនការឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី៧ ព្រមទាំងឧបត្ថម្ភក្រមាចំនួន៤០ ឧបករណ៍តេស្តចំនួន៥ប្រអប់ និងថវិកាមួយចំនួន នៅសង្កាត់ភូមិរបស់ សង្កាត់ព្រៃ-

អង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង នាថ្ងៃទី១៩ ខែមករា ឆ្នាំ ២០២៣។

-ចូលរួមជាមួយនឹងគណៈប្រតិភូក្រសួងអភិវឌ្ឍន៍ជនបទ ដឹកនាំដោយឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ចុះត្រួតពិនិត្យផ្លូវពីរខ្សែ ស្ថិតនៅក្នុងឃុំព្រះពន្លា ឃុំសំយោង ឃុំបន្ទាយក្រាំង ឃុំរាជមន្ទីរ ឃុំញរ ក្នុងស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣។

❈ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-នាំយកអំណោយរួមមាន៖ អង្ករ ទឹកស៊ីអ៊ីវ ទឹកត្រី ប៊ីចេង ស្ករ-ស ភួយ ភេសជ្ជៈ និងថវិកាមួយចំនួន ជូនលោកតាលោកយាយជួបការលំបាក ចំនួន១៧០គ្រួសារ មកពីភូមិចក ភូមិ១ សង្កាត់ព្រះពន្លា ភូមិកន្ទួត សង្កាត់ភ្លៀត ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២២។




-ចូលរួមពិធីប្រគល់សញ្ញាបត្រដល់និស្សិតជ័យលាភីថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ហ៊ុន ម៉ាណែត** ប្រធានគណៈកម្មាធិការអាហារូបករណ៍សិស្សនិស្សិតក្រីក្ររបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** នៅសកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១២ ខែមករា ឆ្នាំ២០២៣។

-ជាអធិបតីភាពក្នុងពិធីសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋចំនួន៤ឃុំ គឺ៖ឃុំស្វាយចេក ឃុំទ្រាស ឃុំស្លក្រាម និងឃុំរលួស ដើម្បីអបអរសាទរខួបលើកទី៤៤ នៃទិវាជ័យជម្នះ ៧មករា (៧ មករា ១៩៧៩ - ៧ មករា ២០២៣) នៅស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៤ និងថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៣ ។

❈នាព្រឹកថ្ងៃទី៤ ខែមករា ឆ្នាំ២០២៣ លោកជំទាវ **មុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចុះជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សា និងមន្ត្រីសាលាសង្កាត់ផ្សារដើមថ្កូវ ព្រមទាំងឧបត្ថម្ភនូវឧបករណ៍ធ្វើតេស្តរហ័សរកកូវីដ-១៩ ចំនួន១.៣៥០ តេស្ត និងថវិកាមួយចំនួន។



❈នាព្រឹកថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **ទឹម ផន** លេខាធិការគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ ស្មៀន នគរបាលប៉ុស្តិ៍រដ្ឋបាល និងប្រធានមណ្ឌលសុខភាព ដើម្បីស្ដាប់របាយការណ៍ និងបានជំរុញលើកទឹកចិត្តដល់អាជ្ញាធរមូលដ្ឋានដែលបានខិតខំបំពេញតួនាទីភារកិច្ច ដោយស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការថែរក្សាសន្តិសុខ សណ្ដាប់ធ្នាប់ ការផ្ដល់សេវាសាធារណៈ និងការដោះស្រាយបញ្ហាប្រឈមជូនប្រជាពលរដ្ឋបានទាន់ពេលវេលា ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នៅឃុំជ្រៃ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង។

❈ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាគណៈអធិបតីភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងលើកទិសដៅការងារបន្ត នៅ

សាលាស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២២។

-ជាគណៈអធិបតីភាពក្នុងពិធីជួបសំណេះសំណាល និងចែកអំណោយដល់សិស្សនិទ្ទេស A ចំនួន៧នាក់ និងសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិទូទាំងស្រុកអូររាំងឪសរុប៣៩៤នាក់ នៅសាលាស្រុកអូររាំងឪ ព្រមទាំងចុះត្រួតពិនិត្យទីតាំងទន្លេស្ងួតដែលគ្រោងដាំដើមផ្កាចំនួន ១.០០០.០០០គុម្ព ដើម្បីទទួលទេវតាឆ្នាំថ្មី នាពេលខាងមុខ នៅភូមិព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី៥ ខែមករា ឆ្នាំ២០២៣។

❈ឯកឧត្តម **ឌុំ ចន់** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមគ្រួសារអតីតយុទ្ធជន ព្រមទាំងរៀបចំអាហារសាមគ្គីជូនបងប្អូនដែលជាសមាជិកក្រុមគ្រួសារអតីតយុទ្ធជន នៅក្នុងក្រុងខេមរភូមិន្ទ ខេត្តកោះកុង នាថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣។

❈ឯកឧត្តម **ខឹម លាង** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំត្រពាំងគរ ទាំង១០ភូមិ ដើម្បីឈ្វេងយល់អំពីសកម្មភាពលើការងារជុំវិញការចុះឈ្មោះបោះឆ្នោត ការផ្ដល់សេវាសាធារណៈ និងគោលនយោបាយភូមិ ឃុំមានសុវត្ថិភាពទាំង៧ចំណុច ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនដល់គ្រួសារសព និងស្ត្រីសម្រាលកូន នៅឃុំត្រពាំងគរ ស្រុកជើងព្រៃ ខេត្តកំពង់ចាម នាថ្ងៃទី៤ ខែមករា ឆ្នាំ២០២៣។

-នាំយកឧបករណ៍តេស្តរហ័សកូវីដ-១៩ របស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ប្រគល់ជូនមណ្ឌលសុខភាពកំពង់ចាម និងកំពង់សៀម នៅការិយាល័យសុខាភិបាលស្រុក ក្រុងកំពង់ចាម ចំនួន៥កេស ស្មើនឹង



៣.៣៧៥ឧបករណ៍តេស្ត សម្រាប់បម្រើជូនប្រជាជនក្នុងមូលដ្ឋាន និងសាលាក្រុងកំពង់ចាមចំនួន១០០ឧបករណ៍តេស្ត ជូនសាលាស្រុកកំពង់សៀមចំនួន១០០ឧបករណ៍តេស្ត សម្រាប់បម្រើជូនមន្ត្រីរាជការក្នុងសាលាក្រុង ស្រុក នៅខេត្តកំពង់ចាម នាព្រឹកថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣។

❈នាថ្ងៃទី៣ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **ញ៉ុង សុខ** សមាជិកគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ នគរបាលប៉ុស្តិ៍រដ្ឋបាល ប្រធានមណ្ឌលសុខភាព ស្មៀនឃុំ និងប្រធានភូមិទាំងអស់ នៃឃុំអន្លង់វិល ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ ព្រមទាំងបាននាំយកអំណោយដ៏ថ្លៃថ្លារបស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភារួមមាន៖ ប្រដាប់ធ្វើតេស្តរហ័សចំនួន១០ប្រអប់ អាវយឺត៥ ដែលលាងដៃធំ២ តូច១០ សម្រាប់ប្រើប្រាស់ក្នុងឃុំ និងឧបត្ថម្ភថវិកាមួយចំនួន។

❈នាព្រឹកថ្ងៃទី៩ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **ច្រឹង គឹមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា និងលោកជំទាវ **ស៊ី វណ្ណថា** សមាជិកាគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីបើកការដ្ឋានពង្រីក និងលើកកម្រិតគុណភាពផ្លូវជាតិលេខ៧ប្រវែង៤៥.៤៨៩គីឡូម៉ែត្រ ចាប់ពីរង្វង់មូលស្គន់ ដល់រង្វង់មូលគល់ស្ពានគីហ្សូណា (ក្រុងកំពង់ចាម) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **វ៉ាង វិនធៀន** ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅខេត្តកំពង់ចាម។

❈ឯកឧត្តម **ច្រឹង គឹមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តសម្ដេចឧត្តមទេពញាណ

**ហ៊ុន ណេង** ចំនួន៥៥នាក់ ព្យាបាលជំងឺជូនប្រជាពលរដ្ឋចំនួន៣៤៣នាក់ ព្រមទាំងប្រគល់អំណោយរបស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភានូវឧបករណ៍តេស្តរហ័សជូនមន្ទីរពេទ្យខេត្តចំនួន២កេស (១.៣៥០ឧបករណ៍) ជូនមន្ទីរពេទ្យបង្អែក ការិយាល័យស្រុកប្រតិបត្តិស្ទឹងត្រង់ចំនួន២កេសស្មើនឹង១.៣៥០ឧបករណ៍ មន្ត្រីសាលាស្រុកចំនួន១០០កេសស្មើនឹង២.៨០០ឧបករណ៍ និងឧបត្ថម្ភថវិកាមួយចំនួនដល់ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៅឃុំទួលព្រះឃ្លាំង ស្រុកស្ទឹងត្រង់ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៣។

-នាំយកអំណោយរបស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នូវឧបករណ៍តេស្តរហ័សចំនួន៥កេសស្មើនឹង៣.៣៧៥ឧបករណ៍ និងចែកឧបករណ៍តេស្តចំនួន១០០ ទៅសាលាស្រុកសម្រាប់ចែកបន្តដល់មណ្ឌលសុខភាព នៅការិយាល័យសុខាភិបាល ស្រុកប្រតិបត្តិកំពង់ចាម និងកំពង់សៀម ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣។

❈ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋនៅភូមិកំពង់សំរោង ឃុំកំពង់សំរោង និងភូមិម៉ាក់ប្រាង្គ ឃុំកំពង់គ្រែង ស្រុកទឹកឈូ ខេត្តកំពត នាថ្ងៃទី២ ខែមករា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋរងគ្រោះដោយខ្យល់កន្ត្រាក់ចំនួន១០០គ្រួសារ ព្រមទាំងផ្ដល់អំណោយក្នុងមួយគ្រួសារៗ ទទួលបាន៖ អង្ករចំនួន២០គីឡូក្រាម មី ស្ករ-ស និងអំបិល នៅភូមិត្រពាំងរពៅ សង្កាត់ព្រែកត្នោត ក្រុងបូកគោ ខេត្តកំពត នារសៀលថ្ងៃទី៥ ខែមករា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួនសម្រាប់ចូលរួមចំណែកសាងសង់សាលារៀន នៅភូមិស្រែ សង្កាត់ត្រើយកោះ ក្រុងកំពត ខេត្តកំពត នារសៀលថ្ងៃទី៦ ខែមករា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជានេសាទនៅភូមិដូនតោក (ត្រើយកោះ) សង្កាត់ត្រើយកោះ ក្រុងកំពត ខេត្តកំពត នារសៀលថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋ និងចែកជូនកង្ហារចំនួន៣គ្រឿង ធុងបាស់ (Speaker) ចំនួន១ ព្រមទាំងនាំយកសៀវភៅ និងថវិកាមួយចំនួនចែកសិស្សានុសិស្ស នៅភូមិត្រពាំងសង្កែ ឃុំត្រពាំងសង្កែ នៅស្រុកទឹកឈូ ខេត្តកំពត នាថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣។

❈ឯកឧត្តម **សត ណារី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភា ឯកឧត្តម **ស្ងួន លន់** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភា និងលោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធី៖

-ជួបសំណេះសំណាលជាមួយនឹងមាតា បិតា អាណាព្យាបាល និងសិស្សនិទ្ទេស A ឆ្នាំ២០២២ ចំនួន១១១នាក់ទូទាំងខេត្តសៀមរាប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៅសាលាខេត្តសៀមរាប នាថ្ងៃទី៦ ខែមករា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងនិវត្តជនក្នុងខេត្តសៀមរាបចំនួន១.១១១នាក់ ក្នុងឱកាសអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៤ឆ្នាំ (៧ មករា ១៩៧៩-៧ មករា ២០២៣) នៃទិវាជ័យជម្នះ ៧ មករា និងកម្មវិធីក្រោមអធិបតីភាពខ្ពង់ខ្ពស់របស់សម្ដេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិ នៅសួនច្បារមុខព្រះរាជដំណាក់ក្រុងសៀមរាប ខេត្តសៀមរាប នាព្រឹកថ្ងៃទី៧ ខែមករា ឆ្នាំ២០២៣។

❈នាថ្ងៃទី៨ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **សត ណារី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៤ ឆ្នាំ (៧ មករា ១៩៧៩-៧ មករា ២០២៣) នៃទិវាជ័យជម្នះ ៧ មករា នៅស្រុកអង្គរជុំ ខេត្តសៀវរាប។

❈នាថ្ងៃទី៧ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **ម៉ូង ម៉័យ** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាអធិបតីភាពក្នុងពិធីបែបប្រពៃណីរបស់បងប្អូនជនជាតិដើមភាគតិចក្នុងខេត្តរតនគិរី (កាប់ក្របីសែនព្រេន) ដើម្បី

សុំសេចក្តីសុខជូនដល់ប្រជាជន នៅក្នុងខេត្តរតនគិរី។

❈លោកជំទាវ **ឃួន យុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖



-ជាអធិបតីភាពក្នុងពិធីបើកបវេសនកាលឆ្នាំសិក្សា ២០២២-២០២៣ និងពិធីប្រគល់រង្វាន់លើកទឹកចិត្តជូនដល់សិស្សដែលបានប្រឡងជាប់សញ្ញាបត្រទុតិយភូមិនិទ្ទេស A ទទួលបានកុំព្យូទ័រយួរដៃចំនួន១គ្រឿង និងនិទ្ទេសB ទទួលបានថវិកាមួយចំនួន នៅវិទ្យាល័យ ហ៊ុន សែន ត្បែង នៅភូមិបាគង ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី២ ខែមករា ឆ្នាំ២០២៣។



-ជួបសំណេះសំណាលជាមួយនឹងឪពុកម្តាយរបស់យុវសិស្សឈ្មោះ **ពុធ ត្វមិន្ទ** ដែលបានប្រឡងជាប់សញ្ញាបត្រទុតិយភូមិទទួលបាននិទ្ទេសA នៅសាលាវិទ្យាល័យ ហ៊ុន សែន ត្បែង មានជីវភាពខ្វះខាត ស្ថិតនៅភូមិស្រង៉ែ ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី៥ ខែមករា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ក្នុងឱកាសពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៤ ទិវាជ័យជម្នះ ៧ មករា (៧ មករា ១៩៧៩-៧ មករា ២០២៣) នៅភូមិតារាម ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី៧ ខែមករា ឆ្នាំ២០២៣។

-ចូលរួមសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ជា ចាន់តូ** អគ្គទេសាភិបាលធនាគារជាតិ នៃកម្ពុជា ក្នុងឱកាសអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៤ នៃទិវាជ័យជម្នះ៧មករា (៧ មករា ១៩៧៩-៧ មករា ២០២៣) នៅមាត់ស្ទឹងសែន ក្រុងស្ទឹងសែន ខេត្តកំពង់ធំ នាថ្ងៃទី៩ ខែមករា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ក្នុងឱកាសពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៤ ទិវាជ័យជម្នះ ៧ មករា (៧ មករា ១៩៧៩-៧ មករា ២០២៣) នៅផែក្មេងលេង ឃុំផាត់សណ្តាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣។



-នាំយកបច្ច័យមួយចំនួនប្រគេនព្រះមេគណខេត្តកំពង់ធំ និងជាព្រះគ្រូចៅអធិការវត្តឥន្ទ្រីយ៍សំវរៈ (ហៅវត្តកំពង់ធំ) ដើម្បីផ្គត់ផ្គង់ដល់បេក្ខសាមណសិស្សក្នុងវត្ត និងសិស្សមកប្រឡងយកវិញ្ញាបនបត្រពុទ្ធិកបឋមសិក្សា (បាលីរង) នៅសាលាពុទ្ធិកបឋមសិក្សាវត្តឥន្ទ្រីយ៍សំវរៈ សង្កាត់ព្រៃកតាហ៊ូ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ នាថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣។

❈នាថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមជាអធិបតីភាពអបអរសាទរពិធីបើកបវេសនកាល ឆ្នាំសិក្សា២០២២-២០២៣ នៅភូមិអូរស្នួល ឃុំតាសាញ ស្រុកសំឡូត ខេត្តបាត់ដំបង នាថ្ងៃទី២ ខែមករា ឆ្នាំ២០២៣។



-ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត មកពីប្រទេសបារាំង ព្យាបាលជំងឺជូនប្រជាពលរដ្ឋនៅស្រុកកំរៀង និងចុះសួរសុខទុក្ខដល់គ្រួសារអតីតគណៈអភិបាល និងអភិបាលរងស្រុកកំរៀង ចំនួន២គ្រួសារ ដែលបានទទួលមរណភាពនាពេលកន្លងទៅ នៅស្រុកកំរៀង ខេត្តបាត់ដំបង នាថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣។



-ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៃសមាគមបេសកកម្មមនុស្សធម៌ប្រចាំនៅកម្ពុជារបស់ប្រទេសបារាំង (AMH) មកព្យាបាលជំងឺជូនប្រជាពលរដ្ឋនៅស្រុកកំរៀង និងចុះសួរសុខទុក្ខ និងជូនពរឯកឧត្តមឧកញ៉ាបណ្ឌិត **ស៊ីន ឃីម** ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៅក្រុងបាត់ដំបង ខេត្តបាត់ដំបង នាថ្ងៃទី១៧ ខែមករា ឆ្នាំ ២០២៣។

❈នាថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **ឡៅ ឆន** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញជាអធិបតីភាពក្នុងពិធីសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋចំនួន ២០០នាក់ ក្នុងឱកាសអបអរសាទរខួបលើកទី៤៤ នៃទិវាជ័យជម្នះ ៧មករា (៧ មករា ១៩៧៩-៧ មករា ២០២៣) នៅឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្ដរមានជ័យ។

❈ឯកឧត្តម **អ៊ឹម លាងហ៊ួ** សមាជិកគណៈកម្មការទី៧ ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមជាគណៈអធិបតីក្នុងពិធីសំណេះសំណាលសួរសុខទុក្ខប្រជាពលរដ្ឋ និងព្រះសង្ឃ ចំនួន១.៩៤៩អង្គ/នាក់ ក្នុងឱកាសអបអរសាទរខួបលើកទី៤៤ នៃទិវាជ័យជម្នះ ៧មករា (៧ មករា ១៩៧៩-៧ មករា ២០២៣) និងនាំយកទេយ្យវត្ថុប្រគេនព្រះសង្ឃ៤៥អង្គ ព្រមទាំងជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាឃុំទាំង៥ ដើម្បីឈ្វេងយល់ពីសភាពការណ៍ទូទៅថ្មីៗព្រមទាំងជូនឧបករណ៍តេស្តរហ័សដល់មណ្ឌលសុខភាពទាំង៣ សាលាស្រុក សាលាឃុំទាំង៥ និងរៀបចំពិសាបាយសាមគ្គី នៅបរិវេណសាលាស្រុកជលគិរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី៨ ខែមករា ឆ្នាំ២០២៣។



-គោរពវិញ្ញាណក្ខន្ធ និងរំលែកមរណទុក្ខក្រុមគ្រួសារសពលោក **ស៊ុំ យាន** អតីតអនុប្រធានមន្ទីរអប់រំយុវជន និងកីឡា ខេត្តកំពង់ឆ្នាំង នៅភូមិដំណាក់ពពូល សង្កាត់កំពង់ឆ្នាំង នាថ្ងៃទី១២ ខែមករា ឆ្នាំ២០២៣។

❈ឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមប្រគល់ពានរង្វាន់ និងបំពាក់មេដាយជូនជ័យលាភីក្នុងការប្រកួតកីឡាទ្រីយ៉ាត្លុងជ្រើសរើសជើងឯកថ្នាក់ជាតិ ប្រចាំឆ្នាំ២០២២ នៅឆ្នេរលេងទឹក នៅក្នុងភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប នាព្រឹកថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២។

-ចូលរួមពិធីប្រណាំងទូកផ្កាចារ សមុទ្រលើកទី១២ ឆ្នាំ២០២២ ដើម្បីអបអរសាទរបុណ្យចូលឆ្នាំថ្មីឆ្នាំសកល ២០២៣ នៅក្នុងភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប នាព្រឹកថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។



-ចូលរួមពិធីបើក និងបិទការប្រកួតបាល់ទាត់ពានរង្វាន់ សមាគមរាជសីហ៍ខេត្តកំពត លើកទី១ ក្នុងឱកាសអបអរសាទរខួបលើកទី៤៤ ទិវាជ័យជម្នះ ៧ មករា (៧ មករា ១៩៧៩-៧ មករា ២០២៣) នៅពហុកីឡដ្ឋានខេត្តកំពត នាព្រឹកថ្ងៃទី៧ និងពេលរសៀលថ្ងៃទី៨ ខែមករា ឆ្នាំ២០២៣។

-ចូលរួមគោរពវិញ្ញាណក្ខន្ធសពលោកតា **រ័ត្ន ទុំ** ជាលោកគ្រូធម្មាចារ្យវត្តឫស្សី នៅគេហដ្ឋានសពស្ថិតក្នុងភូមិរបងក្រាស់ ឃុំកំពង់ត្រាចខាងកើត ស្រុកកំពង់ត្រាច ខេត្តកំពត នាព្រឹកថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣។

❈ឯកឧត្តម **សាយ បូរិន** សមាជិកគណៈកម្មការទី៨ ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមប្រជុំពិនិត្យ និងពិភាក្សាជាមួយនឹងគណៈកម្មការសាងសង់សាលាមួយខ្នងមានប្រាំបន្ទប់ នៃសាលាបឋមសិក្សាពោធិ៍ព្រឹក្ស នៅឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីសំណេះសំណាលជាមួយនឹងលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឆ្នាំសិក្សា២០២១-២០២២ និងអបអរសាទរខួបលើកទី៤៤ទិវាជ័យជម្នះ ៧ មករា (៧ មករា ១៩៧៩-៧ មករា ២០២៣) នៅភូមិទួលវិហារ ឃុំជីរោទិ៍ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៥ ខែមករា ឆ្នាំ២០២៣។

-ជាអធិបតីភាពក្នុងពិធីក្រុងពាលីសាងសង់អគារសិក្សាមួយខ្នងមានប្រាំបន្ទប់ នៅសាលាបឋមសិក្សាពោធិ៍ព្រឹក្ស ស្ថិតនៅ ភូមិពោធិ៍ព្រឹក្សកើត ឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី៥ ខែមករា ឆ្នាំ២០២៣។

❈ឯកឧត្តម **សួន លន់** សមាជិកគណៈកម្មការទី១០ ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងអាជ្ញាធរភូមិ ឃុំ និងប្រជាពលរដ្ឋ នៃស្រុកអង្គរធំ ក្នុងឱកាសអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៤ទិវាជ័យជម្នះ ៧ មករា នៅឃុំជប់តាត្រាវ ស្រុកអង្គរធំ ខេត្តសៀមរាប នាព្រឹកថ្ងៃទី៨ ខែមករា ឆ្នាំ២០២៣។

-ជាអធិបតីភាពក្នុងកិច្ចប្រជុំបូកសរុប និងវាយតម្លៃលទ្ធផលការងារប្រចាំខែមករា ឆ្នាំ២០២៣ និងលើកទិសដៅការងារបន្ត នៅស្រុកអង្គរធំ ខេត្តសៀមរាប នាព្រឹកថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣។

❈នាព្រឹកថ្ងៃទី៧ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **សួន លន់** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភា និងលោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធអតីតយុទ្ធជនពលីជីវិត ដើម្បីជាតិមាតុភូមិ នៅចេតិយ ៧មករា ខេត្តសៀមរាប។

❈នាព្រឹកថ្ងៃទី២១ ខែមករា ឆ្នាំ២០២៣ លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញចូលរួមរំលែកទុក្ខជាមួយនឹងក្រុមគ្រួសារសព ឧបាសិកា **ឡុង សារ៉េត** នៅភូមិបឹងដូនប៉ា សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប៕

# សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ




❈នាថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ សមាជិកព្រឹទ្ធសភាប្រចាំភូមិភាពទី៥ បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបើកការដ្ឋានស្តារ និងលើកកម្រិតគុណភាពផ្លូវជាតិលេខ៣១ និងលេខ៣៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅភូមិជុំគ្រៀល ឃុំជុំគ្រៀល ស្រុកទឹកឈូ ខេត្តកំពត។



❈នាព្រឹកថ្ងៃទី៩ ដល់ថ្ងៃទី១០ ខែមករា ២០២៣ សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញទៅចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ដូសជំរុញ (ដូសទី៦) នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា។




❈ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជា ជេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីខួបទី២៥ឆ្នាំ នៃក្រុមហ៊ុនផារ៉ាហ្គុន អេឌ្យូខេសិន ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នៅសណ្ឋាគារហៃយ៉ាតរីជិនស៊ី រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣។

❈ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបាន៖



-ចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាល និងបំពាក់គ្រឿងឥស្សរិយយសជូននិវត្តជនកាកបាទក្រហមកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា នៅកាកបាទក្រហមកម្ពុជា រាជធានីភ្នំពេញ នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២។

-ចូលរួមពិធីពិសាអាហារសាមគ្គីគម្រប់ខួប១០ឆ្នាំ សមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ (TYDA) ក្រោមអធិបតីភាពឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅសាលមហាស្រពកោះពេជ្រ នាថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២។

❈នាថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៣ ឯកឧត្ដម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្ដម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីជួបសំណេះសំណាល និងពិសាអាហារសាមគ្គីជាមួយនឹងបងប្អូនអ្នកសារព័ត៌មានលើកទី៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាលពិព័រណ៍កោះពេជ្រ។



❈នាថ្ងៃទី១២ ខែមករា ឆ្នាំ២០២៣ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានចូលរួមគោរពវិញ្ញាណក្ខន្ធសពឧបាសិកា **នូ សំបូរ** ម្ដាយបង្កើតលោកជំទាវ **ស៊ិន សុជាតិ** ប្រធាននាយកដ្ឋាន នៃខុទ្ទកាល័យឯកឧត្ដមអគ្គលេខាធិការព្រឹទ្ធសភា នៅវត្តកោះប្រាក់ ភូមិកោះប្រាក់ ឃុំភូមិធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល។



❈នាថ្ងៃទី១៧ និងថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា និងឯកឧត្ដម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិ ស្ដីពីក្របខ័ណ្ឌគណនេយ្យភាពជាពហុវិស័យសម្រាប់ឆ្លើយតបនឹងជំងឺរបេង ក្នុងចំណោមអន្តរក្រសួង ទីភ្នាក់ងារអង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍ នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ។

❈នាថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ ឯកឧត្ដម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីពិសាអាហារថ្ងៃត្រង់ទទួលឯកឧត្ដម Damien Regnard សមាជិកព្រឹទ្ធសភាបារាំង តំណាងឱ្យប្រជាពលរដ្ឋបារាំងនៅឯបរទេស និងជាសមាជិកគណៈកម្មការវប្បធម៌ អប់រំ និងទំនាក់ទំនង នៃព្រឹទ្ធសភាបារាំង នៅភោជនីយដ្ឋាន Khéma រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៣ ឯកឧត្ដម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញជាកិត្តិយសក្នុងពិធីកាត់ឫសសីមាព្រះវិហារ និងឆ្លងសមិទ្ធផលនានា នៅវត្តវិហារបិទមាសទិសឧត្តរ ក្រោមអធិបតីភាពឯកឧត្ដមនាយឧត្ដមសេនីយ៍កិត្តិបណ្ឌិត **ហ៊ីង ប៊ុនហៀង** នាយករងខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី ព្រមទាំងប្រគេនបច្ច័យដល់វត្តវិហារបិទមាស សម្រាប់បន្តកសាងសមិទ្ធផលថ្មីៗបន្ថែម នៅឃុំព្រែកស្ដែង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។

❈នារាត្រីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា និងឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញពិសាអាហារការងារជាមួយនឹងគណៈប្រតិភូអង្គការចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ដឹកនាំដោយលោកស្រី Jimin Jeong ប្រធានគ្រប់គ្រង G Foundation នៃអង្គការចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ នៅសង្កាត់បឹងកេងកង ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

❈ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមរំលែកទុក្ខជាមួយនឹងក្រុមគ្រួសារលោក **ទឹត ខែមរ៉ា** ប្រធាននាយកដ្ឋានសំណង់ នៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងគោរពវិញ្ញាណក្ខន្ធសពឧបាសក **នាង មិន** នៅក្នុងវត្តទឹកថ្លា រាជធានីភ្នំពេញ នារសៀលថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣។

-ចូលរួមរំលែកទុក្ខជាមួយនឹងក្រុមគ្រួសារលោកវេជ្ជបណ្ឌិតឧត្តមសេនីយ៍ទោ **សៅ ស៊ីដូណា** នាយករងសុខាភិបាលក្រសួងការពារជាតិ និងគោរពវិញ្ញាណក្ខន្ធសពឧបាសិកា **ស៊ុន ស៊ីណៃ** នៅផ្ទះលេខ១០ ផ្លូវលេខ៩ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ នាល្ងាចថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៣។

❈នាថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **ខឹម ឈាង** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញទៅចូលរួមបុណ្យគម្រប់ខួប១០០ថ្ងៃ សពលោកឧត្តមសេនីយ៍ឯក **អន សុធារ័ត្ន** ជាអង្គរក្សសម្តេចតេជោ នៅភូមិបឹងរំ ឃុំឫស្សីកែវ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ។



❈នាថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ឹង ឈាងហ៊ួ** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីបើក និងបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងលើកទិសដៅការងារបន្តឆ្នាំ២០២៣ របស់ក្រសួងធម្មការ និងសាសនា នៅទីស្តីការក្រសួង។

❈លោកជំទាវ **ឃួន ឃុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពឧបាសិកា **នូ សំបូរ** ម្តាយបង្កើតលោកជំទាវ **ស៊ិន សុជាតិ** ជំនួយការខុទ្ទកាល័យឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា នៅវត្តកោះប្រាក់ ស្រុកកៀនស្វាយ ខេត្តកណ្ដាល នារសៀលថ្ងៃទី១២ ខែមករា ឆ្នាំ២០២៣៕

# ការទទួលពាក្យបណ្តឹង

❈នៅខែមករា ឆ្នាំ២០២៣ គណៈកម្មការទី១ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន៧ករណី បញ្ជូនទៅក្រសួង ស្ថាប័នពាក់ព័ន្ធមានសមត្ថកិច្ចដោះស្រាយចំនួន៥ករណី កំពុងពិនិត្យសិក្សាចំនួន១១ករណី (សល់ពីឆ្នាំ២០២២ ចំនួន៧ករណី) ទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពាក្យបណ្តឹងពីក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន២ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន៥ករណី និងទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការចំនួន២ករណី៕

# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែធ្នូ និងប្រចាំឆ្នាំ២០២២ ព្រមទាំងកំណត់ទិសដៅការងារឆ្នាំ២០២៣



ឯកឧត្តម អ៊ុំ សារឹទ្ធ អធិបតីភាពក្នុងកិច្ចប្រជុំបូកសរុបប្រចាំខែធ្នូ និងប្រចាំឆ្នាំ២០២២

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែធ្នូ និងឆ្នាំ២០២២ ព្រមទាំងលើកទិសដៅការងារសម្រាប់ខែមករា និងឆ្នាំ២០២៣ ក្រោមអធិបតីភាពឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា នាព្រឹកថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចាប់ពីអនុប្រធាននាយកដ្ឋានឡើង។

មានប្រសាសន៍ក្នុងកិច្ចប្រជុំនាឱកាសនោះ ឯកឧត្តម **អ៊ុំ សារឹទ្ធ** បានជម្រាបជូនអង្គប្រជុំអំពីសភាពការណ៍អន្តរជាតិ តំបន់ និងសភាពការណ៍ជាតិ ព្រមទាំងធ្វើការបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងខែធ្នូ និងឆ្នាំ២០២២ថា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានអនុវត្តការងារសម្រេចបានលទ្ធផលកើនឡើងលើមុខងារទាំង៥ ជាងឆ្នាំ២០២១។ លទ្ធផលទាំងនេះ ជាសូចនាករនៃការគ្រប់គ្រង ដឹកនាំ និងជំនាញរបស់មន្ត្រីក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

ដើម្បីបង្កើនប្រសិទ្ធផល ឱ្យកាន់តែល្អប្រសើរថែមទៀត អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានបើកវគ្គបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពលើការងារគ្រប់គ្រង ដឹកនាំ និងប្រមូលធាតុចូលក្នុងការកសាងផែនទីបង្ហាញផ្លូវឆ្ពោះទៅសម្រេចឱ្យបានផែនការយុទ្ធសាស្ត្រ ២០២១-២០៣០ សម្រាប់ការអភិវឌ្ឍព្រឹទ្ធសភាឱ្យក្លាយជាសភាទំនើប។ ជាមួយគ្នានោះ ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានបញ្ជាក់ថា ស្របតាមបរិបទ នៃការវិវឌ្ឍថ្មី អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានដាក់ចេញវិធានការគោលនយោបាយនានា ជាពិសេសការអនុវត្តគោលនយោបាយ “ ថវិកាតិចសកម្មភាពច្រើន ” ប្រកបដោយជោគជ័យ ដោយធានាបាននិរន្តរភាព និងប្រក្រតីភាពក្នុងការអនុវត្តថវិកាឆ្នាំ២០២២។

សម្រាប់ទិសដៅការងារបន្ត ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានណែនាំដល់គ្រប់អង្គភាពចំណុះអគ្គលេខាធិកាដ្ឋានព្រឹទ្ធសភា បង្កើនការផ្តល់សេវាជូនសមាជិក សមាជិកាព្រឹទ្ធសភាឱ្យបានកាន់តែមានគុណភាព ប្រសិទ្ធភាព និងទាន់ពេលវេលា ព្រមទាំងគ្រប់ជ្រុងជ្រោយលើមុខងារទាំង៥របស់ព្រឹទ្ធសភា។ ព្រមជាមួយគ្នានោះ មន្ត្រីរាជការទាំងអស់ត្រូវបន្តយកចិត្តទុកដាក់ចូលរួមប្រយុទ្ធប្រឆាំងនឹងការរីករាលដាល នៃជំងឺកូវីដ-១៩ ដោយបន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមវិធានការ និងការណែនាំរបស់ក្រសួងសុខាភិបាលឱ្យបានម៉ត់ចត់ និងល្អប្រសើរ៕

(អត្ថបទ៖ វង់ សុជាតិ រូបភាព៖ គង់ យ៉ារីន)



ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែធ្នូ និងប្រចាំឆ្នាំ២០២២

# ឯកឧត្តម អ៊ុំ សារឹទ្ធ អនុញ្ញាតឱ្យនិស្សិតកម្ពុជា ទទួលជ័យលាភីអាហារូបករណ៍ ប្រទេសនូវែលសេឡង់ចូលជួបសំណេះសំណាល និងទទួលអនុសាសន៍




*ឯកឧត្តម អ៊ុំ សារឹទ្ធ អគ្គលេខាធិការព្រឹទ្ធសភា*

នាព្រឹកថ្ងៃទី៤ ខែមករា ឆ្នាំ២០២៣ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់របស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យនិស្សិតកម្ពុជា ទទួលជ័យលាភីអាហារូបករណ៍ប្រទេសនូវែលសេឡង់ចំនួន១៥នាក់ ចូលជួបសំណេះសំណាល និងទទួលអនុសាសន៍ មុននឹងចេញដំណើរទៅសិក្សាថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត នៅតាមសាកលវិទ្យាល័យនានា នៃប្រទេសនូវែលសេឡង់។

ក្នុងនាមសម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឯកឧត្តម **អ៊ុំ សារឹទ្ធ** បានអបអរសាទរចំពោះក្មួយៗនិស្សិតទាំង១៥រូប ដែលទទួលបានអាហារូបករណ៍ពីប្រទេសនូវែលសេឡង់ ដើម្បីទៅសិក្សាថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត នៅប្រទេសណូវែលសេឡង់។ នេះជាឱកាសមួយដ៏ល្អប្រសើរក្រៃលែងដែលក្មួយៗនិស្សិតនឹងទទួលបាននូវចំណេះដឹងថ្មីៗ ដើម្បីពង្រឹងសមត្ថភាពខ្លួនសម្រាប់ជាមូលដ្ឋានក្នុងការអភិវឌ្ឍខ្លួនផង និងប្រទេសជាតិផង។ ជាងនេះទៀត គឺជាការរួមចំណែកក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការល្អរវាងប្រទេសទាំងពីរកម្ពុជា និងប្រទេសនូវែលសេឡង់ផងដែរ។

ឯកឧត្តម **អ៊ុំ សារឹទ្ធ** បានសង្កត់ធ្ងន់ថា រឿងមួយដែលក្មួយៗនិស្សិតចាំបាច់ត្រូវធ្វើគឺ ត្រូវគោរពច្បាប់ប្រទេស និងច្បាប់សាលាឱ្យបានខ្ជាប់ខ្ជួន ដើម្បីបង្ហាញអំពីសេចក្ដីថ្លៃថ្នូរក្នុងនាមជាកូនខ្មែរឱ្យក្រុមនិស្សិតដែលមកពីបណ្ដាប្រទេសនានាបានឃើញ ត្រូវសម្របខ្លួនរៀនរស់នៅ រៀនទំនាក់ទំនងជាមួយនឹងប្រជាពលរដ្ឋខ្មែរដែលរស់នៅក្នុងប្រទេសនូវែលសេឡង់ និងនិស្សិតផ្សេងៗទៀតដែលកំពុងសិក្សានៅទីនោះស្រាប់ ព្រមទាំងផ្សព្វផ្សាយអំពីសភាពការណ៍ថ្មីៗ ការអភិវឌ្ឍថ្មីៗរបស់ប្រទេសកម្ពុជាបច្ចុប្បន្ន ដើម្បីទាក់ទាញឱ្យពួកគាត់មកធ្វើទេសចរណ៍នៅប្រទេសកម្ពុជា។

ឯកឧត្តម **អ៊ុំ សារឹទ្ធ** បានផ្ដាំផ្ញើដល់និស្សិតទាំងអស់ថា ទោះបីជាក្មួយៗត្រូវទៅសិក្សានៅសាលាផ្សេងៗគ្នាក៏ពិតមែន ប៉ុន្តែត្រូវចេះសាមគ្គីភាពផ្ទៃក្នុង សហការគ្នា ទំនាក់ទំនងគ្នា និងចេះជួយយកអាសាគ្នាទៅវិញទៅមក ក្នុងនាមជាខ្មែរដូចគ្នា ដូចសុភាសិតខ្មែរយើងពោលថា "នៅផ្ទះម្ដាយទីទៃ នៅព្រៃម្ដាយតែមួយ"។

សូមជម្រាបថា អាហារូបករណ៍របស់ប្រទេសនូវែលសេឡង់ គឺត្រូវបានគ្រប់គ្រង និងចាត់ចែងដោយក្រសួងការបរទេស និងពាណិជ្ជកម្ម (MFAT) របស់ប្រទេសនូវែលសេឡង់ ដើម្បីជួយគាំទ្រដល់និស្សិតទូទាំងពិភពលោកក្នុងការបន្តការសិក្សាថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។ និស្សិតអន្តរជាតិប្រហែល១.០០០នាក់ ត្រូវបានជ្រើសរើសឱ្យមកធ្វើការសិក្សានៅក្នុងប្រទេសនូវែលសេឡង់ជារៀងរាល់ឆ្នាំ ដោយនិស្សិតភាគច្រើនមកពីតំបន់ប៉ាស៊ីហ្វិក អាស៊ី អាហ្វ្រិក អាមេរិកឡាទីន និងតំបន់ការ៉ាប៊ីន៕

(អត្ថបទ៖ វ៉ាន់ ពិសិដ្ឋ រូបភាព៖ គឹម សិទ្ធី)



*ទិដ្ឋភាពនៃពិធីជំនួបទទួលអនុសាសន៍*

## សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី២ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជាអធិតីភាពក្នុងកិច្ចប្រជុំពិភាក្សាការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងបន្តអនុវត្តតួនាទី ភារកិច្ចឱ្យបានល្អប្រសើរ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីអគ្គនាយក អគ្គនាយិកា នៃអគ្គនាយកដ្ឋានទាំង៥ អគ្គាធិការ និងថ្នាក់ដឹកនាំអង្គភាពចំណុះអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ចាប់ពីអនុប្រធាននាយកដ្ឋានឡើង។



❈នាព្រឹកថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំត្រួតពិនិត្យអំពីការរៀបចំ Mobile App របស់ព្រឹទ្ធសភា នៅសាលប្រជុំពិសេសIII វិមានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីឯកឧត្តមអគ្គលេខាធិការរង អគ្គនាយក អគ្គនាយិកា អគ្គនាយករង នៃអគ្គនាយកដ្ឋានទាំង៥ មន្ត្រីជំនាញ នៃនាយកដ្ឋានព័ត៌មានវិទ្យា តំណាងមជ្ឈមណ្ឌលសភាអាស៊ី (PCAsia) និងតំណាងក្រុមហ៊ុន CODE's DONE។



❈នាព្រឹកថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល និងថ្លែងអំណរគុណចំពោះក្រុមគ្រូពេទ្យដែលបានអញ្ជើញមកចាក់ថ្នាំបង្ការជំងឺកូវីដ-១៩ ដូសទី៦ ជូនដល់ថ្នាក់ដឹកនាំ សមាជិក សមាជិកា មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងក្រុមគ្រួសារ នៃព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម នៅវិមានព្រឹទ្ធសភា ពីថ្ងៃទី៩ ដល់ថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំពិនិត្យពិភាក្សាលើការងារសំខាន់ៗសម្រាប់អនុវត្តនាពេលខាងមុខរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើងវិមានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីឯកឧត្តមអគ្គលេខាធិការរង អគ្គនាយក អគ្គនាយិកា អគ្គនាយករង នៃអគ្គនាយកដ្ឋានទាំង៥ អគ្គាធិការ និងថ្នាក់ដឹកនាំ នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ចាប់ពីថ្នាក់ប្រធាននាយកដ្ឋានឡើង។



❈នាព្រឹកថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ គណៈកម្មការពិនិត្យ កែសម្រួលសេចក្តីព្រាងសេចក្តីសម្រេចស្តីពី គោលការណ៍ផ្តល់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការ ដែលមានស្នាដៃឆ្នើមនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានប្រជុំក្រោមអធិបតីភាពឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា នៅសាលពិសេសជាន់ខាងក្រោម វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី៩ ខែមករា ឆ្នាំ២០២៣ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃប្រទេសបារាំងនៅកម្ពុជា ចុះពិនិត្យ និងព្យាបាលជំងឺទូទៅឥតយកកម្រៃជូនប្រជាពលរដ្ឋក្រីក្រនៅវត្តល្វាក្រោម ហៅវត្តឧទម្ពរ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រដ្ឋសភា និងក្រុមប្រឹក្សាធម្មនុញ្ញ បានជួបប្រជុំដើម្បីពិនិត្យពិភាក្សា និងរៀបចំកែប្រែប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការ នៃស្ថាប័ននីតិប្បញ្ញត្តិ ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា និងសហការី ឯកឧត្តម **ព្រហ្ម វិចិត្រ អរុណ្ឌារ** អគ្គលេខាធិការរងក្រុមប្រឹក្សាធម្មនុញ្ញ និងសហការី ព្រមទាំងតំណាងអគ្គលេខាធិការដ្ឋានរដ្ឋសភា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❋ចាប់ពីថ្ងៃទី៩ ដល់ថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានរៀបចំទីកន្លែងចាក់ថ្នាំបង្ការជំងឺកូវីដ-១៩ ដូសទី៦ ជូនដល់ថ្នាក់ដឹកនាំ សមាជិក សមាជិកា មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងក្រុមគ្រួសារនៃព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា។



❋នាព្រឹកថ្ងៃទី៣ ខែមករា ឆ្នាំ២០២៣ អគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងលើកទិសដៅការងារអនុវត្តបន្តឆ្នាំ២០២៣ ក្រោមអធិបតីភាពឯកឧត្តម **កែវ ចាន់ណា** អគ្គនាយកនៃអគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា។




❋នារសៀលថ្ងៃទី៣ ខែមករា ឆ្នាំ២០២៣ អគ្គនាយកដ្ឋានស្រាវជ្រាវ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងលើកទិសដៅការងារអនុវត្តបន្តឆ្នាំ២០២៣ ក្រោមអធិបតីភាពលោកជំទាវ **សួន ពុធថាវី** អគ្គនាយិកានៃអគ្គនាយកដ្ឋានស្រាវជ្រាវ ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានស្រាវជ្រាវ នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី៤ ខែមករា ឆ្នាំ២០២៣ អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២២ និងលើកទិសដៅការងារអនុវត្តបន្តឆ្នាំ២០២៣ ក្រោមអធិបតីភាពឯកឧត្តម **ម៉ុន ឫទ្ធា** អគ្គនាយក នៃអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា៕




❈នាព្រឹកថ្ងៃទី៥ ខែមករា ឆ្នាំ២០២៣ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងលើកទិសដៅការងារអនុវត្តបន្តឆ្នាំ២០២៣ ក្រោមអធិបតីភាពឯកឧត្តម **ទេព ចាន់អុនឫទ្ធីរក្ស** អគ្គនាយកស្ដីទី នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា៕




❈នាព្រឹកថ្ងៃទី៦ ខែមករា ឆ្នាំ២០២៣ អគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២២ និងលើកទិសដៅការងារអនុវត្តបន្តឆ្នាំ២០២៣ ក្រោមអធិបតីភាពឯកឧត្តម **ឈឹម សុទ្ធគុណ** អគ្គនាយក នៃអគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា៕



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នារសៀលថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២ លោកជំទាវ **សាយ ចាន់ណាក់** នាយិការងខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា បាននាំយកថវិការបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** និងលោកជំទាវ ចូលរួមបុណ្យសព មហាឧបាសិកាពុទ្ធសាសននូបត្ថម្ភក៍ **ស៊ុយ ស៊ុំម៉ាឡៃ** ត្រូវជាម្តាយបង្កើតរបស់លោកជំទាវ **ពុំ ចន្ទីនី**។



❈នារសៀលថ្ងៃទី៩ ខែមករា ឆ្នាំ២០២៣ លោកជំទាវ **សាយ ចាន់ណាក់** នាយិការងខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា បានអញ្ជើញសួរសុខទុក្ខ និងនាំយកថវិការបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ឧបត្ថម្ភថ្លៃព្យាបាលជំងឺ លោកស្រី **ម៉េត គឹមឡាយ** ស្នូះសរសៃបេះដូង ដែលសម្រាកព្យាបាល នៅគ្លីនិកព្យាបាលជំងឺបេះដូងពិភពថ្មី ស្ថិតនៅភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី៥ ខែមករា ឆ្នាំ២០២៣ លោកជំទាវ **សាយ ចាន់ណាក់** នាយិការងខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា បានអញ្ជើញនាំយកថវិការបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** និងលោកជំទាវ ចូលរួមព្រះរាជពិធីចម្រើនព្រះជន្មវស្សាវឌ្ឍនមង្គល ថ្វាយសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត **ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងព្រះជន្មាយុ ៩២ ចូល៩៣ព្រះជន្មវស្សា នៅវត្តឧណ្ណាលោម ដែលស្ថិតនៅសង្កាត់ជ័យជន្ទះ ខណ្ឌដូនពេញ រាជធានីពេញភ្នំពេញ។



❈នាព្រឹកថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៣ លោកជំទាវ **សាយ ចាន់ណាក់** នាយិការងខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា បាននាំយកថវិការបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** និងលោកជំទាវ ចូលរួមរំលែកទុក្ខសពឧបាសិកា **លាត នាង** ត្រូវជាម្តាយក្មេករបស់លោកឧកញ៉ា **អ៊ឹង ឆៃឡួន** អគ្គនាយកវិទ្យុ-ទូរទស្សន៍ហង្សមាស និងរស្មីហង្សមាស ដែលបានទទួលមរណភាពកាលពីថ្ងៃពុធ ទី១១ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង៧:១៥នាទីយប់ អាយុ៩២ឆ្នាំ ដោយជរាពាធ។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាថ្ងៃសុក្រ ទី៣០ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **លី ឡេង** នាយកខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ ព្រឹទ្ធ-សភា តំណាងឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** អនុប្រធានទី១ព្រឹទ្ធសភា បានអញ្ជើញចុះពិនិត្យវឌ្ឍនភាពនៃការកសាងកំផែងវត្ត និងសមិទ្ធផលផ្សេងៗទៀត ព្រមទាំងនាំយកថវិកាទៅទូទាត់ថ្លៃសំណង់ និងថ្លៃពលកម្មជាង នៅវត្តពង្ររង្សី ហៅវត្តជ្រៃម្រាក់ ស្ថិតនៅឃុំគោកគង់កើត ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង។



❈នាថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង១៥:៣០ នាទី គណៈកម្មការត្រួតពិនិត្យបេឡាសោធននិវត្តន៍ បានប្រជុំក្រោមអធិបតីភាពលោកជំទាវ **រត្ន ឆវីលក្ខណ៍** ប្រធានគណៈកម្មការត្រួតពិនិត្យបេឡាសោធននិវត្តន៍ ដើម្បីបូកសរុបលទ្ធផលការងារត្រួតពិនិត្យ និងស្ដាប់របាយការណ៍ស្ដីពីប្រតិបត្តិការចរន្តសាច់ប្រាក់ប្រចាំឆ្នាំ២០២២ ជាមួយនឹងអង្គភាពគ្រប់គ្រងមូលនិធិសង្គមកិច្ចមន្ត្រីរាជការ នៃអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលប្រជុំពិសេសក្រោមវិមានព្រឹទ្ធសភា។



❈នាថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង១៤:៣០ នាទី គណៈកម្មការត្រួតពិនិត្យបេឡាសោធននិវត្តន៍ បានប្រជុំ ក្រោមអធិបតីភាពលោកជំទាវ **រត្ន ឆវីលក្ខណ៍** ប្រធានគណៈកម្មការត្រួតពិនិត្យបេឡាសោធននិវត្តន៍ ដើម្បីបូកសរុបលទ្ធផលការងារត្រួតពិនិត្យ និងស្ដាប់របាយការណ៍ស្ដីពីប្រតិបត្តិការចរន្តសាច់ប្រាក់ប្រចាំឆ្នាំ២០២២ ជាមួយនឹងអង្គភាពគ្រប់គ្រងបេឡាសោធននិវត្តន៍ និងសោធន៍បាត់បង់សម្បទាវិជ្ជាជីវៈ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលប្រជុំពិសេសក្រោម វិមានព្រឹទ្ធសភា។




ព្រឹទ្ធសភា
SENAT/SENATE